Cambodian
Women's
Crisis
Center

# ជួយស្ត្រីដើម្បីអោយស្ត្រីជួយខ្លួនឯង

# របាយការណ៍ប្រចាំឆ្នាំ



២០២៤

## សេចក្តីផ្តើម

បើទោះជាមានយន្តការជាតិនិងយន្តការទាំងឡាយ ត្រូវបានដាក់ឲ្យអនុវត្តន៍ ដើម្បីលើកកម្ពស់សមភាពយេនឌ័រនៅកម្ពុជាយ៉ាងណាក៏ដោយ សមភាពយេនឌ័រនៅកម្ពុជានៅមិនទាន់ទទួលបានភាពស្មើគ្នាគ្រប់ជ្រុងជ្រោយទាំងស្រុងនោះទេ ទោះបីជាមានការខិតខំប្រឹងប្រែងរួមគ្នាពីស្ថាប័នរាជរដ្ឋាភិបាល និងសង្គមស៊ីវិលនានាក៏ដោយ។ ស្ត្រីភាគច្រើនដែលរស់នៅទីជនបទដាច់ស្រយាល ជាពិសេសក្រុមស្ត្រីដែលមានចំនួនតិចនៅក្នុងសង្គមមិនទាន់ទទួលបាននូវសិទ្ធិជាមូលដ្ឋានរបស់ខ្លួននោះពេញលេញនៅឡើយទេ ដោយស្ត្រីនិងក្មេងស្រីទាំងនោះ មិនទទួលបាននូវភាពស្មើគ្នាក្នុងការទទួលសេវាថែទាំសុខភាព ការអប់រំ អាជីពការងារ និងការចូលរួមផ្នែកនយោបាយ។ មួយវិញទៀត អំពើហិង្សាក៏បាននឹងកំពុងកើតមានឡើងជារៀងរាល់ថ្ងៃ ដែលបង្កឲ្យមានអស្ថេរភាពក្នុងគ្រួសារ ភាពក្រីក្រ និងការធ្លាក់ចុះនូវធនធានមនុស្ស។ កត្តាទាំងនេះបានជះឥទ្ធិពល មិនល្អមកលើប្រជាជនជាច្រើន ជាពិសេសគឺស្ត្រី ដែលធ្វើឲ្យពួកគេពុំអាចប្រើប្រាស់សិទ្ធិមនុស្សជាសកលរបស់ខ្លួនបាន។

អង្គការ CWCC បាននឹងកំពុងធ្វើការយ៉ាងជិតស្និត ជាមួយម្ចាស់ជំនួយដោយទទួលបានការគាំទ្រ និងការគិតគូរអំពីបំលាស់ប្តូរនិន្នាការនៅក្នុងការផ្តល់មូលនិធិរបស់ម្ចាស់ជំនួយ។ ជាមួយគ្នានេះដែរ អង្គការ CWCC បានបង្កើនកិច្ចសហការជាមួយស្ថាប័នរដ្ឋារាជភិបាល ដៃគូរអភិវឌ្ឍន៍ សង្គមស៊ីវិល និងស្ថាប័នពាក់ព័ន្ធ ដែលជាយន្តការមួយក្នុងការផ្តល់ការគាំទ្រ និងអន្តរាគមដ៏មានប្រសិទ្ធិភាព ដែលជាកម្លាំងចលករក្នុងការជំរុញធ្វើឲ្យប្រសើរឡើងនូវសមភាពយេនឌ័រនៅកម្ពុជា។

អង្គការ CWCC ផ្តោតការយកចិត្តទុកដាក់ក្នុងការធ្វើអន្តរាគមន៍ និងផ្តល់សេវាដើម្បីកាត់បន្ថយអំពើហិង្សា និងពង្រឹងសិទ្ធអំណាចដល់ស្ត្រី ជាពិសេសពាក់ព័ន្ធនឹងបញ្ហាអំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ ការរំលោភបំពានផ្លូវភេទ និងការជួញដូរផ្លូវភេទ ការជួញដូរស្ត្រី និងកុមារ និងការទទួលបានភាពស្មើគ្នារបស់ក្មេងស្រីក្នុងវិស័យអប់រំ ។

### វិធីសាស្ត្ររបស់អង្គការ



**តំបន់គោលដៅរបស់អង្គការ**

- រាជធានីភ្នំពេញ៖ ការិយាល័យប្រចាំតំបន់ និង មណ្ឌលសុវត្ថិភាព
- ខេត្តសៀមរាប៖ ការិយាល័យប្រចាំតំបន់ និង មណ្ឌលសុវត្ថិភាព
- ខេត្តបន្ទាយមានជ័យ៖ ការិយាល័យប្រចាំតំបន់ និង មណ្ឌលសុវត្ថិភាព
- ខេត្តកំពង់ធំ៖ ការិយាល័យប្រចាំតំបន់
- ខេត្តកំពង់ស្ពឺ៖ បណ្តាញគោលដៅ

**ទស្សនវិស័យ**

ស្ត្រី និងកុមារី រស់នៅដោយសន្តិភាព សុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ ហើយរីករាយនឹងសិទ្ធិមនុស្សជាសកលរបស់ខ្លួន។

**បេសកម្ម**

ពង្រឹងសិទ្ធិអំណាចដល់ស្ត្រី និងកុមារីឲ្យទាមទារសិទ្ធិជាសកលរបស់ខ្លួន ដើម្បីទទួលបាននូវសុវត្ថិភាពផ្ទាល់ខ្លួន និងចូលរួមដោយស្មើភាពគ្នាក្នុងការងារសហគមន៍ សង្គមស៊ីវិល ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងចូលរួមក្នុងសកម្មភាពនយោបាយ សង្គម និងវប្បធម៌។

**ទិសដៅរួម**

ចូលរួមពង្រឹងសិទ្ធិអំណាចដល់ស្ត្រី និងកុមារីដែលរងគ្រោះ និងងាយរងគ្រោះ តាមរយៈការទប់ស្កាត់ ការការពារ និងការតស៊ូមតិ ដើម្បីលើកកម្ពស់ឲ្យមានសង្គមមួយដែលមាន សន្តិភាព សមភាពយេនឌ័រ និងក្តីមេត្តា ករុណា។

**តម្លៃស្នូល**

**សេចក្តីថ្លៃថ្នូរ៖** មនុស្សគ្រប់រូប ដោយមិនគិតពីឋានៈ ភេទ អសមត្ថភាព និងភាពខុសប្លែកដទៃទៀត គឺត្រូវរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ។

**ភាពយុត្តិធម៌៖** មនុស្សគ្រប់រូប គួរតែរីករាយ និងទទួលបាននូវសិទ្ធិស្មើគ្នា នៅក្នុងការចូលរួមនៅក្នុងកិច្ចការនយោបាយ និងការអនុវត្ត ដែលអាចទទួលបាននូវការបែងចែកអំណាច ធនធាន និងឱកាសស្មើៗគ្នា។

**គណនេយ្យភាព៖** ធនធាន និងការទទួលខុសត្រូវ សម្រាប់ធ្វើការសម្រេចចិត្ត ត្រូវបានប្រើប្រាស់ជាមធ្យោបាយមួយ សម្រាប់ធ្វើឲ្យមានតម្លាភាព និងអាចឆ្លើយតបទៅនឹងម្ចាស់ជំនួយ ដែលស្របតាមធម្មនុញ្ញភាព ព្រមទាំងបំពេញតម្រូវការសហគមន៍។

**កម្មវិធីរបស់អង្គការ**

គោលដៅរួមរបស់អង្គការនឹងត្រូវបានសម្រេចឡើងតាមរយៈកម្មវិធីយុទ្ធសាស្ត្រចំនួនបួន៖

យុទ្ធសាស្ត្រទី១: កម្មវិធីទប់ស្កាត់

យុទ្ធសាស្ត្រទី២: កម្មវិធីការពារ

យុទ្ធសាស្ត្រទី៣: កម្មវិធីស្វែងរកមតិគាំទ្រ

យុទ្ធសាស្ត្រទី៤: ការអភិវឌ្ឍន៍អង្គការ

## ១. កម្មវិធីទប់ស្កាត់

### ១.១ គម្រោងរៀបចំសហគមន៍

ការអប់រំ និងពង្រឹងសិទ្ធិអំណាចដល់ប្រជាពលរដ្ឋក្នុងសហគមន៍ មន្ត្រីមានកាតព្វកិច្ច អ្នកដឹកនាំសហគមន៍ និងអាណាព្យាបាល ដើម្បីផ្លាស់ប្តូរអាកប្បកិរិយារបស់ពួកគាត់ទាក់ទងនឹងសិទ្ធិស្ត្រី និងកុមារ គឺជាយុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រផ្សេងៗទៀតរបស់អង្គការ CWCC ក្នុងការដោះស្រាយបញ្ហាអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅកម្ពុជា។ គម្រោងរៀបចំសហគមន៍បានផ្តល់ការកសាងសមត្ថភាពដល់មន្ត្រីមានកាតព្វកិច្ចដែលរួមមាន អ្នកដឹកនាំសហគមន៍ អាជ្ញាធរមូលដ្ឋាន និងមន្ត្រីប៉ូលីស អំពីសិទ្ធិស្ត្រី សិទ្ធិរបស់ជនមានពិការភាព អំពើហិង្សាទាក់ទងយេនឌ័រ ច្បាប់អំពើហិង្សាក្នុងគ្រួសារ ច្បាប់ប្រឆាំងការជួញដូរ និងលើកកំពស់ការយល់ដឹងដល់ប្រជាពលរដ្ឋក្នុងសហគមន៍ ។

តាមរយៈកិច្ចសហការជាមួយមន្ទីរកិច្ចការនារីខេត្តគោលដៅគម្រោង បានបង្កើតនិងដំណើរការក្រុមការងារឆ្លើយតបអំពើហិង្សាទាក់ទងយេនឌ័រចំនួន៧ក្រុម ក្នុងស្រុកគងពិសី និងស្រុកសាមគ្គីមុនីជ័យ ក្នុងខេត្តកំពង់ស្ពឺ និងស្រុកអង្គរធំ ស្រុកប្រាសាទបាគង និងស្រុកស្វាយលើក្នុងខេត្តសៀមរាប និងស្រុកប្រាសាទសំបូរ ស្រុកសន្ទុក និងស្រុកប្រសាទបាល័ង្គ ក្នុងខេត្តកំពង់ធំ និងខណ្ឌឫស្សីកែវក្នុងរាជធានីភ្នំពេញដែលមានសមាជិកសរុបចំនួន ៣០៨ នាក់ (ស្ត្រី១៨៥នាក់)។ ក្នុងឆ្នាំ ២០២៤គម្រោងបានបន្តធ្វើការដោយផ្ទាល់ជាមួយក្រុមគាំទ្រស្ត្រី និងយុវជនចំនួន១៨ក្រុមដែលមានសមាជិកចំនួន៥១០នាក់ (ស្រី៤៧៦) និងក្រុមទាំងអស់បានដើរតួនាទីជាភ្នាក់ងារសម្រាប់ធ្វើអោយមានការផ្លាស់ប្តូរនៅក្នុងសហគមន៍របស់ ពួកគេរៀងៗខ្លួន តាមរយៈការលើកកំពស់ការយល់ដឹង ទៅដល់ប្រជាពលរដ្ឋក្នុងសហគមន៍ប្រមាណជា ៦,២៦៣នាក់ (ស្រី២,៨៩៤) ដែលក្នុងនោះ២៧២៨ (៧៦%)ជាស្ត្រី ។

### ១.២ បញ្ចប់ការដាក់ទណ្ឌកម្មលើកុមារ និងការលើកកម្ពស់ការចិញ្ចឹមកូនបែបវិជ្ជមាននៅកម្ពុជា

អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC) អង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍ (COCD) និងអង្គការគាំពារកុមារដែលងាយទទួលរងគ្រោះ (VCAO) បានសហការគ្នាដើម្បីអនុវត្តគម្រោងមួយដែលមានឈ្មោះថា "បញ្ចប់ការដាក់ទណ្ឌកម្មកុមារ និងលើកកម្ពស់ការចិញ្ចឹមបីបាច់កូនបែបវិជ្ជមាននៅប្រទេសកម្ពុជា-EVAC" នៅតាមសហគមន៍ និងសាលាគោលដៅ ដែលស្ថិតនៅក្នុងខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ ដែលគម្រោងនេះផ្សារភ្ជាប់ទៅនឹងចំណេះដឹង ពីការចិញ្ចឹមកូនបែបវិជ្ជមាន កិច្ចការពារកុមារ ផលប៉ះពាល់នៃការប្រើអំពើហិង្សាលើកុមារ ការបំពានគ្រឿងញៀន សិទ្ធិកុមារ និងវិធីសាស្ត្រទំនាក់ទំនងដោយអហិង្សា រវាងឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំក្នុងគ្រួសារសហគមន៍ និងក្នុងសាលារៀន ដោយបានការគាំទ្រគម្រោងថវិកាពីម្ចាស់ជំនួយ terre des hommes Deutschland e.V.។

ក្រុមគោលដៅសំខាន់ៗរួមមាន គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ (គ.ក.ន.ក ) មកពីស្រុកគោលដៅចំនួន៥ មន្ត្រីការិយាល័យសង្គមកិច្ច និងសុខមាលភាពសង្គម មន្ត្រីថ្នាក់ស្រុក/ក្រុង មន្ត្រីជំនាញនៃមន្ទីរកិច្ចការនារី មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងខេត្តគោលដៅទាំងបីគឺ ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ បានទទួលបានការបណ្តុះបណ្តាល ស្តីពីកិច្ចការពា រកុមារ និងការចិញ្ចឹមកូនបែបវិជ្ជមាន ដើម្បីបណ្តុះបណ្តាលនិងអប់រំផ្សព្វផ្សាយបន្តដល់ឪពុកម្តាយ អាណាព្យាបាលឬអ្នកថែទាំ។ ដូច្នេះឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ នឹងកើនឡើងនូវចំណេះដឹងពីវិធីសាស្ត្រទំនាក់ទំនង

ជាមួយកូន យល់ដឹងពីការចិញ្ចឹមកូនបែបវិជ្ជមាន និងផ្លាស់ប្តូរទម្លាប់ឬឥរិយាបថ ព្រមទាំងការប្រព្រឹត្តទៅលើការចិញ្ចឹមកូន បែបដាក់ទណ្ឌកម្មធ្ងន់ធ្ងរ និងប្រើហិង្សា មកជាការចិញ្ចឹមកូនបែបវិជ្ជមាន និងការផ្តល់ភាពកក់ក្តៅ ដើម្បីឱ្យកុមារមានសីលធម៌ អាកប្បកិរិយាល្អ និងការប្រព្រឹត្តល្អទាំងនៅក្នុងគ្រួសារ សាលារៀននិងសហគមន៍។ ដើម្បីឆ្លើយតបនឹងគោលបំណងនេះ អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC) បានសហការជាមួយគ្រូបង្គោលមកពីក្រសួងកិច្ចការនារី និង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានរៀបចំវគ្គបណ្តុះបណ្តាល រយៈពេល ០៥ថ្ងៃ ស្តីពី"កិច្ចការពារកុមារ និងការចិញ្ចឹមកូនបែបវិជ្ជមាន" ដោយមានអ្នកចូលរួមចំនួន ៤១នាក់ រួមទាំងស្ត្រី ២៩ នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលការពារកុមារ និងការចិញ្ចឹមកូនបែបវិជ្ជមាន។ បន្ទាប់ពីការការបណ្តុះបណ្តាល TOTថ្នាក់ជាតិ គ្រូបង្គោលថ្នាក់មន្ទីរកិច្ចការនារី និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនតិសម្បទា បានធ្វការបណ្តុះបណ្តាលបន្ត ទៅ សមាជិកគកនក (CCWC) ចំនួន ៧២ នាក់ រួមទាំងស្ត្រី ៥១ នាក់ ត្រូវបានបណ្តុះបណ្តាលអំពីការការពារកុមារ និងការចិញ្ចឹមកូនបែបវិជ្ជមាន។

គម្រោងបានបង្កើតក្រុមឪពុកម្តាយគម្រូ (PIG)ចំនួន ១៨ ក្រុម ជាមួយនឹងសមាជិក ២៨៣នាក់ (២២៨ នាក់ជាស្រី)។ បន្ទាប់ពីបង្កើតក្រុមរួច ក្រុមឪពុកម្តាយគម្រូ (PIG) បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាស ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍នៃការចិញ្ចឹមកូនបែបវិជ្ជមាន និងធ្វើទស្សនកិច្ចសិក្សារបស់ក្រុមឪពុកម្តាយគម្រូ ដែលមានអ្នកចូលរួម ៤៩ នាក់ រួមមានសមាជិក PIG និងបុគ្គលិកពី VCAO កំពង់ឆ្នាំង, COCD ពោធិ៍សាត់ និង CWCC កំពង់ធំ ដែលបានចែករំលែកបទពិសោធន៍ អំពីការចិញ្ចឹមកូនបែបវិជ្ជមាន។ លទ្ធផលនៃការ ទស្សនកិច្ច អ្នកចូលរួមបានចូលរួមយ៉ាងសកម្ម តាមរយៈក្រុមពិភាក្សា ការចែករំលែកបទពិសោធន៍ពីក្រុមឪពុក ម្តាយគម្រូមកពីខេត្តសៀមរាប។ ក្រុមឪពុកម្តាយគម្រូបានរៀនសូត្រ និងប្តេជ្ញាចែករំលែកចំណេះដឹងទៅក្រុម PIG របស់ពួកគេបន្ទាប់ពីត្រលប់មកវិញ។

គម្រោងក៏បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការបណ្តុះបណ្តាលគ្រូបង្គោលមកពី DoEYS ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡា និងដៃគូសម្ព័ន្ធចំនួនបីបានពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការលើកកម្ពស់វិន័យបែបវិជ្ជមាន និងការគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាពនៅក្នុងសាលារៀន អ្នកចូលរួមចំនួន ៣៨នាក់ (ស្ត្រី ១៧ នាក់)។ បន្ទាប់ពីការការបណ្តុះបណ្តាល TOT ថ្នាក់ជាតិគ្រូបង្គោលពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំ យុវជន និងកីឡា បានធ្វើការការបណ្តុះ បណ្តាលបន្តដល់នាយកសាលា និងគណៈកម្មា ធិការគាំទ្រសាលាចំនួន ៧៨នាក់ (ស្ត្រី១៦នាក់) បានពង្រឹងការយល់ដឹងរបស់ពួកគេអំពី កិច្ចការពារកុមារ វិន័យបែបវិជ្ជមាន ដើម្បីដោះស្រាយអំពើហិង្សាលើកុមារ ការដាក់ទណ្ឌកម្ម និងការរំលោភបំពានគ្រឿងញៀន នៅក្នុងសាលារៀន។ បន្ទាប់ពី TOT ពី គ្រូបង្គោលពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំ យុវជន និងកីឡា នាយក សាលាបានធ្វើការផ្សព្វផ្សាយបន្តចំនួន៣០ដង ដល់គ្រូបង្រៀនចំនួន ៤៨៣នាក់ (ស្ត្រី២៧៣នាក់) ដើម្បីលើកកម្ពស់ វិន័យបែបវិជ្ជមាន និងការការពារកុមារ។ វគ្គទាំងនេះបានបង្កើនការយល់ដឹងរបស់គ្រូបង្រៀនអំពីការដាក់ទណ្ឌកម្ម និងសិទ្ធិកុមារ ដែលរួមចំណែកដល់ការគ្រប់គ្រងថ្នាក់រៀនកាន់តែប្រសើរ និងសុខុមាលភាពសិស្ស។

គម្រោងបានបង្កើតក្លឹបកុមារចំនួន ១៨ ដែលមានសិស្សសរុប ២៧០ នាក់ រួមទាំងក្មេងស្រី ១៨៥ នាក់។ បន្ទាប់ពីការបង្កើតក្លឹបកុមារ បុគ្គលិកគម្រោងសហការជាមួយគណៈកម្មាធិការឃុំស្ត្រី និងកុមារ និងគណៈកម្មាធិការគាំទ្រសាលារៀន បានផ្តល់វគ្គបណ្តុះបណ្តាលបំប៉នសមត្ថភាពដល់ក្រុមក្លឹបកុមារ ចំនួន៦ក្លឹប

ពីអំពើហិង្សាលើកុមារ ការដោះស្រាយជម្លោះ ដោយអហិង្សា ការដាក់ទណ្ឌកម្មលើរាងកាយ សិទ្ធិកុមារ ការការពារកុមារ ផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន និងរបៀបរាយការណ៍ករណីអំពើហិង្សា និងស្វែងរកសេវាពាក់ព័ន្ធ។ បន្ទាប់ពីការបណ្តុះបណ្តាល ក្លឹបកុមារបានធ្វើការផ្សព្វផ្សាយចំនួន ១៣៥ដង ដល់សិស្សនិងកុមារនៅក្នុងសហគមន៍ចំនួន ៣៥០៥នាក់ រួមទាំងក្មេងស្រី ១៨៨៩ នាក់ ដែលផ្តោតលើប្រធានបទ សំខាន់ៗ ដូចជា អំពើហិង្សាលើកុមារ ការដោះស្រាយជម្លោះគ្មានអំពើហិង្សា ការដាក់ទណ្ឌកម្ម សិទ្ធិកុមារ ការការពារកុមារ និងការរំលោភបំពានគ្រឿងញៀន។គម្រោងនេះក៏បានសម្របសម្រួលកិច្ចប្រជុំប្រចាំត្រីមាសចំនួន49ដង ជាមួយសមាជិកក្លឹបកុមារ ដោយផ្តោតលើការពិនិត្យគោលនយោបាយ តួនាទី ការទទួលខុសត្រូវ និងយុទ្ធសាស្ត្រសម្រាប់ការលើកកម្ពស់ការយល់ដឹងប្រកបដោយប្រសិទ្ធភាព។ គម្រោងបានចែកកង់ចំនួន៨៣នាក់ និងសម្ភារៈសិក្សាដល់សិស្សដែលមានតម្រូវការចំនួន២៧០នាក់។ ជាមួយគ្នានេះដែរ គម្រោងបានរៀបចំ ទស្សនកិច្ចសិក្សារបស់ក្រុមក្លឹបកុមារនៅក្នុងខេត្តកំពង់ឆ្នាំង ជាលទ្ធផលនៃការទស្សនកិច្ច កុមារបានចូលរួមយ៉ាងសកម្ម តាមរយៈក្រុមពិភាក្សា ការផ្លាស់ប្តូរបទពិសោធន៍រវាងក្លឹបកុមារនៅក្នុងតំបន់គោលដៅរបស់អង្គការ VCAO និងទទួលបាននូវមេរៀនរៀនសូត្រល្អៗ ដើម្បីយកទៅអនុវត្តក្នុងតំបន់គោលដៅរៀងៗខ្លួន និងយល់ដឹងពីការដឹកនាំក្រុម បញ្ហា ប្រឈម និងការដោះស្រាយ។

ក្រុមកុមារ និងយុវជនក្នុងគម្រោង E-VAC ចំនួន ០៦ នាក់ បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ជាមួយកុមារ និងយុវជន លើការរៀបចំផែនការជាតិ ស្តីពីការបង្ការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សា លើកុមារ ឆ្នាំ២០២៤-២០២៨។ បន្ទាប់ពីកិច្ចពិភាក្សា កុមារចំនួន០២នាក់របស់ CWCC មកពីខេត្តកំពង់ធំ ត្រូវបានជ្រើសរើសឱ្យ ចូលរួមក្នុងកិច្ចប្រជុំបន្ត នៅរាជធានី ភ្នំពេញ ស្តីពី “ការរៀបចំឯកសារការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងជំហរ និងស្មារតីចូលរួមប្រឆាំងនឹងអំពើហិង្សាលើកុមារ” ដើម្បីពាំនាំពីបញ្ហាសេចក្តីត្រូវការ និងការផ្តល់ធាតុចូលលើសេចក្តី ព្រាងផែនការជាតិស្តីពី ការបង្ការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ដែលបានលើកឡើងនៅក្នុង សេចក្តីថ្លែងការណ៍រួមរបស់កុមារទាក់ទងទៅនឹងការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ដែលផ្តោតសំខាន់លើប្រព័ន្ធកិច្ចការពារកុមារនៅក្នុងសាលារៀន កិច្ចការពារកុមារនៅក្នុងគ្រួសារ និងកិច្ចការពារកុមារនៅក្នុង សហគមន៍ ជាពិសេសកុមាររបស់អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ ក៏ជាអ្នកឡើងអាននូវសេចក្តីថ្លែងការណ៍រួម របស់តំណាងកុមារ និងយុវជនទៅដល់អ្នកធ្វើគោលនយោបាយ មន្ត្រីរាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានាផងដែរ។

គម្រោងនេះបានបង្កើតក្រុមជួយខ្លួនឯង ចំនួន១៦ក្រុម មានសមាជិក ២៧៦ នាក់ ដែលជាក្រុមស្ត្រីដែលមានបណ្ណក្រីក្រ ១ និង២ និងក្រុមហានិភ័យខ្ពស់។ សមាជិក្រុមបានទទួលការបណ្តុះបណ្តាលលើការសន្សំប្រាក់, ការកត់ត្រា, ការយល់ដឹងអំពីហិរញ្ញវត្ថុនិងការគ្រប់គ្រងក្រុមសម្រាប់ គណៈកម្មាធិការ ក្រុមជួយខ្លួនឯង និងផ្តល់មូលនិធិសម្រាប់ក្រុម ជួយខ្លួនងឯង (SHG)។ សមាជិក្រុមបានរៀបចំកិច្ចប្រជុំប្រចាំខែចំនួន៣០ប្រជុំ ក្នុងចំណោមសមាជិកក្រុមជួយខ្លួនឯង (SHG) ទាំង១៨ក្រុម ដើម្បីដាក់ប្រាក់សន្សំ ពិភាក្សានិងធ្វើការសម្រេចចិត្តរួមគ្នាលើប្រាក់កម្ចីនិងបញ្ហាផ្សេងទៀត។ បន្ថែមពីនេះមន្ត្រីកសិកម្មស្រុកធ្វើការបណ្តុះបណ្តាលស្តីពីការចិញ្ចឹមមាន់ដល់ពេទ្យសត្វភូមិចំនួន១៨ភូមិ និងពេទ្យសត្វភូមិបាន បណ្តុះបណ្តាលបន្តដល់សមាជិកក្រុមជួយខ្លួនឯងចំនួន៣៦០នាក់។ គម្រោងបាន ផ្តល់ទុនក្នុងការចិញ្ចឹមមាន់ ដល់សមាជិកក្រុមសន្សំ ដើម្បីបង្កើន

ប្រាក់ចំណូលប្រចាំថ្ងៃ។ បន្ថែមពីនេះមានកិច្ចប្រជុំផ្លាស់ប្តូរពាក់កណ្តាលឆ្នាំរវាងក្រុមជួយខ្លួនឯង ក្នុងចំណោមមួយក្រុមជួយខ្លួនឯងចំនួន៦ក្រុម ដើម្បីចែករំលែក បទពិសោធន៏រវាងគ្នាទៅវិញទៅមក។

គម្រោងនេះផ្តោតសំខាន់ទៅលើក្រុមគ្រួសារក្រីក្រ និងក្រុមគ្រួសារងាយរងគ្រោះនៅក្នុងភូមិចំនួន ១៩២ នៃឃុំចំនួន១៨ ក្នុងស្រុកចំនួន៥ នៃខេត្តកំពង់ឆ្នាំង កំពង់ធំ និងពោធិ៍សាត់។ ក្រុមគោលដៅផ្ទាល់រស់នៅដោយប្រកបរបរដោយការធ្វើកសិកម្មចិញ្ចឹមជីវិតក្រោមលក្ខខណ្ឌមិនច្បាស់លាស់ និង ត្រូវបានជ្រើសរើសតាមកម្រិតនៃភាពក្រីក្រ និងភាពងាយរងគ្រោះ ដោយគិតគូរពីការចូលរួមចំណែកក្នុងសង្គមផងដែរ។

### ១.៣ គម្រោងលើកកម្ពស់ការអប់រំរបស់ក្មេងស្រី

គម្រោងបានផ្តល់កញ្ចប់អាហារូបករណ៍ទៅដល់កុមារីងាយរងគ្រោះ ដែលក្នុងនោះរួមមាន កុមារីមកពីគ្រួសារក្រីក្រ កុមារីដែលមានអំពើហិង្សាក្នុងគ្រួសារ និងកុមារីដែលប្រឈមមុខនឹងការបោះបង់ចោលការសិក្សានៅក្នុងតំបន់គោលដៅនៃខេត្តសៀមរាបនិងរាជធានីភ្នំពេញ។ ក្នុងឆ្នាំ២០២៤ គម្រោងបានផ្តល់កញ្ចប់អាហារូបករណ៍ទៅដល់ក្មេងស្រីចំនួន២០០នាក់ ចាប់ពីកំរិតអនុវិទ្យាល័យ ដល់កំរិតវិទ្យាល័យ (ក្មេងស្រី ១០០នាក់ក្នុងខេត្តសៀមរាប និង ១០០នាក់ក្នុងរាជធានីភ្នំពេញ) ។ គម្រោងបានធ្វើការសហការណ៍ជាមួយក្រុមការងារអប់រំថ្នាក់មូលដ្ឋាន និង ក្រុមសម្របសម្រួលថ្នាក់ស្រុកក្នុងការជ្រើសរើសក្មេងស្រីអាហារូបករណ៍ និងផ្តល់កញ្ចប់អាហារូបករណ៍ ដើម្បីគាំទ្រការសិក្សារបស់ពួកគេ ។ កញ្ចប់អាហារូបករណ៍ដែលគម្រោងបានផ្តល់ជូនរួមមាន សម្ភារះសិក្សា ឯកសណ្ឋានសិស្ស កង់ ប្រាក់ឧបត្ថម្ភប្រចាំខែ ប្រាក់សម្រាប់រៀនគួរក្រៅម៉ោង វគ្គបណ្តុះបណ្តាលកំព្យូទ័រ និងភាសាអង់គ្លេស។ ការផ្តល់ជូនទាំងនេះបានជួយ សម្រួលអោយក្មេងស្រីបន្តការសិក្សា និងទៅរៀនបានទៀងទាត់ ។ ក្មេងស្រីដែលមកពីគ្រួសារក្រីក្រ អាចមានលទ្ធភាពក្នុងការរៀនសូត្រ និងបន្តការសិក្សារបស់ខ្លួនទៅកាន់វគ្គបណ្តុះបណ្តាលជំនាញផ្សេងៗ តាមរយៈកញ្ចប់អាហារូបករណ៍ និងបណ្តាញរបស់គម្រោងជាមួយសាលាជំនាញបណ្តុះបណ្តាលវិជ្ជាជីវៈនានា ។

### ១.៤ គម្រោងពង្រឹងសមត្ថភាពផ្នែកសេដ្ឋកិច្ចដល់ស្ត្រី

កម្មវិធីពង្រឹងសមត្ថភាពផ្នែកសេដ្ឋកិច្ចដល់ស្ត្រីមានគោលបំណង ផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងក្មេងស្រីដែលរស់នៅក្នុងតំបន់គោលដៅ ដើម្បីអោយពួកគាត់មានជីវភាពរស់នៅល្អប្រសើរ ជាមួយនឹងបណ្តាញសង្គមដ៏រឹងមាំមួយ ដើម្បីជួយអោយពួកគាត់យកឈ្នះលើបញ្ហាហិរញ្ញវត្ថុ និងកាត់បន្ថយភាពងាយរងគ្រោះពីរាល់ទម្រង់នៃអំពើហិង្សា។ ក្នុងឆ្នាំ២០២៤ គម្រោងបានធ្វើការជាមួយក្រុមសន្សំ៨១ក្រុម ដែលក្នុងនោះមាន ៤៥ក្រុមក្នុងខេត្តសៀមរាប ២៤ក្រុមក្នុងខេត្តកំពង់ធំ ៦ក្រុមក្នុងខេត្តបន្ទាយមានជ័យ និង៦ក្រុមក្នុងខេត្តកំពង់ស្ពឺ។ ក្រុមទាំងអស់មាន សមាជិកសរុបចំនួន ២៥២៩នាក់ (ស្ត្រី២២៣២នាក់)។ ក្រៅពីនេះគម្រោងក៏បានបន្តគាំទ្រដល់ក្រុមស្ត្រីធ្វើអាជីវកម្ម និងប្រកបមុខរបរផ្សេងៗ ក្នុងគោលបំណងជួយអោយពួកគាត់មានជំនាញ និងអាចរកប្រាក់ ចំណូលសម្រាប់ផ្គត់ផ្គង់ខ្លួនឯង និងគ្រួសារ ។ បន្ថែមពីនេះទៀត គម្រោងបានសម្របសម្រួលស្ត្រី និងក្មេងស្រីក្នុងសហគមន៍ ក្នុងការចូលរៀនជំនាញបច្ចេកទេស និងវិជ្ជាជីវៈ បានចំនួន ២៨នាក់ ទទួលជំនាញ ឆុងកាហ្វេ សាឡន និងកាត់ដេរខោអាវ នៅស្រុកគងពិសី ខេត្តកំពង់ស្ពឺ និងជំនាញសាឡន កាត់ដេរ និងបច្ចេកទេសនៅខេត្តសៀមរាប។

### ១.៥ គម្រោងចំណាកស្រុកសុវត្ថិភាព និងទប់ស្កាត់ការជួញដូរមនុស្ស

គម្រោងបានបន្តធ្វើការជាមួយក្រុមជួយខ្លួនឯងចំនួន១៣ក្រុម មានសមាជិកសរុបចំនួន១៦៧នាក់ (ស្ត្រីចំនួន ១៣៩នាក់) ដែលក្នុងនោះនៅក្នុងស្រុកអូរជ្រៅ មានចំនួន០៧ក្រុម មានសមាជិក៨៥នាក់ (ស្ត្រី

ចំនួន៧២នាក់) ស្រុកម៉ាឡៃមានចំនួន០៣ក្រុម មានសមាជិកចំនួន៣៩នាក់ (ស្ត្រីចំនួន៣០នាក់) និងក្រុងប៉ោយប៉ែត មានចំនួន០៣ក្រុម មានសមាជិកចំនួន៤៣នាក់ (ស្ត្រីចំនួន៣៧នាក់)។ បន្ថែមពីនេះ គម្រោងបានផ្តល់វគ្គបណ្តុះបណ្តាល ដល់មន្ត្រីប៉ូលីសតាមព្រំដែនស្តីពី ចំណាកស្រុកសុវត្ថិភាព និងអំពើជួញដូរមនុស្សបានចំនួន ១៨នាក់ (ស្ត្រីចំនួន៩នាក់)។ ក្នុងឆ្នាំ២០២៤ ជារួមគម្រោងបានធ្វើការផ្សព្វផ្សាយចំណេះដឹងស្តីពីការធ្វើចំណាកស្រុកមានសុវត្ថិភាព និង ទប់ស្កាត់ការជួយដូរមនុស្សទៅកាន់ប្រជាជនក្នុងសហគមន៍សរុបចំនួន ៨៧២១នាក់ (ស្ត្រី៥៤៣៣នាក់)។

## ២. កម្មវិធីការពារ

### ២.១ គម្រោងលើកកម្ពស់បណ្តាញសហគមន៍ ដើម្បីការពារស្ត្រីនិងកុមារពីរាល់ទម្រង់នៃអំពើហិង្សា

គម្រោងបានរៀបចំវគ្គបណ្តុះបណ្តាលដល់សមាជិកបណ្តាញចម្រុះថ្នាក់ស្រុក ដែលពួកគាត់សុទ្ធសឹងតែជាមន្ត្រីមកពីការិយាល័យកិច្ចការនារី ការិយាល័យសង្គមកិច្ច គណៈកម្មាការទទួលបន្ទុកស្ត្រីនិងកុមារ បុគ្គលិកមណ្ឌលសុខភាព ប៉ូលីស និង បុគ្គលដែលជាធនធានសហគមន៍ ដែលមានស្រាប់ក្នុងរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ ខេត្តសៀមរាប និងខេត្តកំពង់ធំ។ ជាលទ្ធផលក្រុមបណ្តាញចម្រុះថ្នាក់ស្រុកបានអន្តរាគមន៍ និងគាំទ្រស្ត្រី និងក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សាទាក់ទងយេនឌ័របានចំនួន៤៨០ករណី ក្នុងចំណោមករណីទាំងនេះមាន៤៣២ករណីជាករណីអំពើរហិង្សាក្នុងគ្រួសារ និង៤០ជាករណីរំលោភបំពានផ្លូវភេទ និង ៨ជាករណីជួញដូរ។ ក្នុងនោះ២៨១ករណីហិង្សាក្នុងគ្រួសារបានសះជា ១៩៨ករណីលែងលះ ៤០ករណីរំលោភបំពានផ្លូវភេទបញ្ជូនទៅប៉ូលីស ៦៧ករណីហិង្សាក្នុងគ្រួសារ និង៨ករណីរំលោភបំពានផ្លូវភេទបញ្ជូនទៅ CWCC និង១៦ករណីករណីហិង្សាក្នុងគ្រួសារកំពុងស្ថិតក្នុងដំណើរការដោះស្រាយ។ តាមរយៈការអន្តរាគមន៍នេះស្ត្រី និងកុមារដែលជាជនរងគ្រោះនៃអំពើហិង្សាបានទទួលសេវាដែលសមស្រប និងឆ្លើយតបទៅតាមតម្រូវការរបស់ពួកគេ ។

### ២.២ គម្រោងជំនួយផ្នែកច្បាប់

ក្នុងឆ្នាំ ២០២៤ មានករណីអំពើហិង្សាទាក់ទងយេនឌ័រចំនួន ៤៥៣ករណី (៤ករណីមានពិការភាព) បានទទួលសេវាកម្មពីការិយាល័យអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ ក្នុងរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ និង ខេត្តកំពង់ធំ ។ ក្នុងចំណោមករណីទាំងនោះ មាន២២៤ជាករណីអំពើហិង្សាក្នុងគ្រួសារ ១០៧ជាករណីរំលោភបំពានផ្លូវភេទ និង ១២២ជាករណីជួញដូរមនុស្ស ។

**ទិន្នន័យករណីអំពើហិង្សាទាក់ទងយេនឌ័រ ឆ្នាំ ២០២៤**

| ករណី | ភ.ព | ប.ជ | ស.រ | ក.ធ | សរុប |
|---|---|---|---|---|---|
| អំពើហិង្សាក្នុងគ្រួសារ | ៣៥ | ២៣ | ១០៥ | ៦១ | ២២៤ |
| ការរំលោភបំពានផ្លូវភេទ | ១២ | ២៦ | ៥២ | ១៧ | ១០៧ |
| ការជួញដូរមនុស្ស | ១១៥ | ៧ | ០ | ០ | ១២២ |
| **សរុប** | ១៦២ | ៥៦ | ១៥៧ | ៧៨ | ៤៥៣ |

*ចំណាំ៖ ភ.ព=ភ្នំពេញ ប.ជ=បន្ទាយមានជ័យ ស.រ=សៀមរាប ក.ធ=កំពង់ធំ*

សម្រាប់ដំណើរការនៃការទទួលករណី ៥៩%នៃជនរងគ្រោះមកទទួលសេវាពីអង្គការ CWCC ដោយខ្លួនឯង និ៣៨%ត្រូវបានបញ្ជូនមកកាន់អង្គការ ។ ៤%ត្រូវបានជួយសង្គ្រោះ ដោយមានការចូលរួមពីអង្គការ CWCC ។

**ភាគរយនៃចំនួនអតិថិជនដែលមកទទួលសេវាពីអង្គការ CWCC ឆ្នាំ២០២៤**




គម្រោងជំនួយផ្នែកច្បាប់បានផ្តល់ការប្រឹក្សាផ្នែកច្បាប់ និងគាំទ្រជនរងគ្រោះដែលសម្រេចចិត្តដាក់ពាក្យបណ្តឹងទៅកាន់តុលាការ តាមរយៈការជួយបំពេញឯកសារពត៌មានពាក្យបណ្តឹង និងស្វែងរកភស្តុតាងនានាដូចជាការសម្របសម្រួលក្នុងការធ្វើកោសល្យវិច្ច័យនៅមន្ទីរពេទ្យ។ ក្នុងចំណោមជនរងគ្រោះទាំងអស់ដែលមកស្វែងរកជំនួយពីអង្គការ CWCC ក្នុងឆ្នាំ២០២៤ មានជនរងគ្រោះចំនួន២៣៤នាក់ស្នើសុំជំនួយផ្នែកច្បាប់ដែលករណីរបស់ពួកគេត្រូវបានបញ្ជូនទៅកាន់តុលាការរាជធានីនិងខេត្ត ។ ជាលទ្ធផលឆ្នាំ២០២៤ មាន១៥៨ករណីត្រូវបានបញ្ចប់តាមដំណើរការផ្លូវច្បាប់របស់តុលាការ ។ ក្នុងចំណោមទាំង១៥៨ ករណីនោះ មាន៧៥ករណីដែលជនប្រព្រឹត្តបទល្មើសត្រូវកាត់ទោសអោយជាប់ពន្ធធានាគារ (៦៨ករណីជាករណីរំលោភបំពានផ្លូវភេទ និង៥ករណីជាករណីអំពើហិង្សាក្នុងគ្រួសារ និង២ករណីជាករណីការជួញដូរមនុស្ស)។

**ទិន្នន័យករណីអំពើហិង្សាទាក់ទងយេឌ័រដែលដាក់ពាក្យបណ្តឹងទៅតុលាការ ឆ្នាំ២០២៤**

| **ករណី** | ករណីក្រោមអាយុ១៨ឆ្នាំ | | | | | ករណីលើអាយុ១៨ឆ្នាំ | | | | | **សរុបរួម** |
|---|---|---|---|---|---|---|---|---|---|---|---|
| | ភ.ព | ប.ជ | ស.រ | ក.ធ | **សរុប** | ភ.ព | ប.ជ | ស.រ | ក.ធ | **សរុប** | |
| អំពើហិង្សាក្នុងគ្រួសារ | ១ | ០ | ០ | ០ | ១ | ២៥ | ៩ | ៩៧ | ២០ | ១៥១ | ១៥២ |
| រំលោភបំពានផ្លូវភេទ | ៨ | ២៣ | ៣៣ | ១៥ | ៧៩ | ០ | ១ | ០ | ០ | ១ | ៨០ |
| ការជួញដូរមនុស្ស | ០ | ០ | ០ | ០ | ០ | ២ | ០ | ០ | ០ | ២ | ២ |
| **សរុប** | ៩ | ២៣ | ៣៣ | ១៥ | ៨០ | ២៧ | ១០ | ៩៧ | ២០ | ១៥៤ | ២៣៤ |

*ចំណាំ៖ ភ.ព=ភ្នំពេញ ប.ជ=បន្ទាយមានជ័យ ស.រ=សៀមរាប ក.ធ=កំពង់ធំ*

**ទិន្នន័យករណីអំពើហិង្សាទាក់ទងយេឌ័រដែលបានជំនុំជម្រះ ឆ្នាំ២០២៤**

| **ករណី** | **ភ.ព** | **ប.ជ** | **ស.រ** | **ក.ធ** | **សរុប** |
|---|---|---|---|---|---|
| អំពើហិង្សាក្នុងគ្រួសារ | ២២ | ៧ | ៥៨ | ០ | ៨៧ |
| រំលោភបំពានផ្លូវភេទ | ៩ | ១៥ | ២៩ | ១៦ | ៦៩ |
| ការជួញដូរមនុស្ស | ២ | ០ | ០ | ០ | ២ |
| **សរុប** | ៣៣ | ២២ | ៨៧ | ១៦ | ១៥៨ |

*ចំណាំ៖ ភ.ព=ភ្នំពេញ ប.ជ=បន្ទាយមានជ័យ ស.រ=សៀមរាប ក.ធ=កំពង់ធំ*

**ទិន្នន័យជនប្រព្រឹត្តបទល្មើសដែលបានបញ្ជូនទៅកាន់ពន្ធធានាគា ឆ្នាំ២០២៤**

| **ករណី** | **ភ.ព** | **ប.ជ** | **ស.រ** | **ក.ធ** | **សរុប** |
|---|---|---|---|---|---|
| អំពើហិង្សាក្នុងគ្រួសារ | ១ | ០ | ០ | ៤ | ៥ |
| រំលោភបំពានផ្លូវភេទ | ៨ | ១៥ | ២៩ | ១៦ | ៦៨ |
| ការជួញដូរមនុស្ស | ២ | ០ | ០ | ០ | ២ |
| សរុប | ១១ | ១៥ | ២៩ | ២០ | ៧៥ |

*ចំណាំ៖ ភ.ព=ភ្នំពេញ ប.ជ=បន្ទាយមានជ័យ ស.រ=សៀមរាប ក.ធ=កំពង់ធំ*

### ២.៣ មណ្ឌលសុវត្ថិភាព

អតិថិជនដែលបានស្នាក់នៅក្នុងមណ្ឌលសុវត្ថាពរបស់អង្គការ CWCC ក្នុងរាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាបក្នុងឆ្នាំ២០២៤ មានចំនួនសរុប៤៣២នាក់ (ដែលក្នុងនោះមានជនរងគ្រោះ៣១៧នាក់ និងសាច់ញាត្តិ១១៥នាក់)។ ក្នុងចំណោមពួកគេទាំងអស់ មានអតិថិជនអាយុក្រោម១៨ឆ្នាំចំនួន២០៣នាក់ (១២៨នាក់ជាជនរងគ្រោះ និង ៧៥នាក់ជាសាច់ញាត្តិ)។ ក្នុងកំឡុងពេលនៃ ការស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាពជនរងគ្រោះទទួលបានការប្រឹក្សាជាបុគ្គលនិងជាក្រុម ដើម្បីកសាងទំនុក ចិត្តនិងភាពជឿជាក់

លើខ្លួនឯង។ អតិថិជនក៏ទទួលបានវគ្គបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ ដូចជាជំនាញ កាត់ដេរ ចំអិនម្ហូប និង ថ្នាក់អក្ខរកម្មផងដែរ ។ បន្ថែមពីនេះទៅទៀត អតិថិជនដែលមិនទាន់គ្រប់អាយុ បានបញ្ជូនអោយទៅសិក្សានៅ សាលារដ្ឋដែលនៅជិតមណ្ឌល ហើយកុមារតូចៗដែលមានអាយុក្រោម៥ឆ្នាំទទួលបាន សេវាថែទាំប្រចាំថ្ងៃ។

**ចំនួនជនរងគ្រោះដែលបានស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាពអង្គការ CWCC ឆ្នាំ២០២៤**

| | **អាយុក្រោម ១៨ឆ្នាំ** | | | | **អាយុលើ ១៨ឆ្នាំ** | | | | |
|---|---|---|---|---|---|---|---|---|---|
| **ជនរងគ្រោះ** | **ភ.ព** | **ប.ជ** | **ស.រ** | **សរុប** | **ភ.ព** | **ប.ជ** | **ស.រ** | **សរុប** | **សរុបរួម** |
| អំពើហិង្សាក្នុងគ្រួសារ | ៦ | ២ | ០ | ៨ | ១១ | ៥ | ១២ | ២៨ | ៣៦ |
| រំលោភបំពានផ្លូវភេទ | ២ | ៤៧ | ២៥ | ៧៤ | ១២ | ៨ | ០ | ២០ | ៩៤ |
| ការជួញដូរមនុស្ស | ៤៣ | ៣ | ០ | ៤៦ | ១៣៩ | ២ | ០ | ១៤១ | ១៨៧ |
| **សរុប** | ៥១ | ៥២ | ២៥ | ១២៨ | ១៦២ | ១៥ | ១២ | ១៨៩ | ៣១៧ |
| | **អាយុក្រោម ១៨ឆ្នាំ** | | | | **អាយុលើ ១៨ឆ្នាំ** | | | | |
| **សាច់ញាតិ** | **ភ.ព** | **ប.ជ** | **ស.រ** | **សរុប** | **ភ.ព** | **ប.ជ** | **ស.រ** | **សរុប** | **សរុបរួម** |
| អំពើហិង្សាក្នុងគ្រួសារ | ១៨ | ២ | ១៥ | ៣៥ | ៨ | ០ | ០ | ៨ | ៤៣ |
| រំលោភបំពានផ្លូវភេទ | ១២ | ០ | ២៦ | ៣៨ | ០ | ១០ | ១២ | ២២ | ៦០ |
| ការជួញដូរមនុស្ស | ២ | ០ | ០ | ២ | ១០ | ០ | ០ | ១០ | ១២ |
| **សរុប** | ៣២ | ២ | ៤១ | ៧៥ | ១១ | ៥ | ៨ | ៤០ | ១១៥ |
| **សរុបរួម** | ៨៣ | ៥៤ | ៦៦ | ២០៣ | ១៧៣ | ២០ | ២០ | ២២៩ | ៤៣២ |

*ចំណាំ៖ ភ.ព=ភ្នំពេញ ប.ជ=បន្ទាយមានជ័យ ស.រ=សៀមរាប*

## ២.៤ គម្រោងសមាហរណកម្ម

ក្នុងឆ្នាំ២០២៤ បន្ទាប់ពីករណីរបស់ជនរងគ្រោះត្រូវបានបញ្ចប់នៅតុលាការ និងស្នាក់នៅមណ្ឌល មានជនរងគ្រោះចំនួន៦៩នាក់និងសាច់ញាតិចំនួន៣៨នាក់ ត្រូវបានធ្វើសមាហរណកម្មទៅតាមសហគមន៍ ដែលពួកគេជ្រើសរើស។ ក្នុងចំណោមជនរងគ្រោះទាំងអស់ មានជនរងគ្រោះចំនួន៤៥នាក់ ទទួលបានជំនួយ ឧបត្ថម្ភគាំទ្រជាថវិកា និងសម្ភារៈសម្រាប់ការរស់នៅ ហើយមានជនរងគ្រោះចំនួន៥នាក់ទទួលបានជំនួយ ឧបត្ថម្ភគាំទ្រការធ្វើអាជីវកម្ម ដើម្បីធានាអោយបានការរស់នៅប្រកបដោយ ឯករាជ្យ និងនិរន្តរភាព ហើយចៀសផុតពីអំពើហឹង្សា និងបរិយាកាសងាយរងគ្រោះណាមួយ។ បុគ្គលិកគម្រោងនៅតែបន្ត តាមដាន ស្ថានភាពរបស់អតិថិជន ដែលបានធ្វើសមាហរណកម្ម តាមរយៈការធ្វើទំនាក់ទំនងជាមួយអាជ្ញាធរក្នុងតំបន់ ការសួរសុខទុក្ខនៅផ្ទះអតិថិជន ដើម្បីធ្វើអោយប្រាកដបាននូវការធ្វើសមាហរណកម្មមានភាពជោគជ័យ ។

**ចំនួនអតិថិជនដែលបានធ្វើសមាហរណកម្មឆ្នាំ ២០២៤**

| ករណី | ជនរងគ្រោះ | | | | | សាច់ញាតិ | | | | | សរុបរួម |
|---|---|---|---|---|---|---|---|---|---|---|---|
| | ភ.ព | ប.ជ | ស.រ | ក.ធ | សរុប | ភ.ព | ប.ជ | ស.រ | ក.ធ | សរុប | |
| អំពើហិង្សាក្នុងគ្រួសារ | ១ | ៣ | ៦ | ៧ | ១៧ | ៣ | ០ | ៤ | ៨ | ១៥ | ៣២ |
| រំលោភបំពានផ្លូវភេទ | ១ | ១ | ១៦ | ៨ | ២៦ | ០ | ០ | ១១ | ១២ | ២៣ | ៤៩ |
| ការជួញដូរមនុស្ស | ២៦ | ០ | ០ | ០ | ២៦ | ០ | ០ | ០ | ០ | ០ | ២៦ |
| **សរុប** | ២៨ | ៤ | ២២ | ១៥ | ៦៩ | ៣ | ០ | ១៥ | ២០ | ៣៨ | ១០៧ |

*ចំណាំ៖ ភ.ព=ភ្នំពេញ ប.ជ=បន្ទាយមានជ័យ ស.រ=សៀមរាប ក.ធ=កំពង់ធំ*

## ៣. កម្មវិធីស្វែងរកមតិគាំទ្រ

### ៣.១ ការសហការណ៍ជាមួយរាជរដ្ឋាភិបាល

តំណាងអង្គការ CWCC បានចូលរួមក្នុងពិធីផ្សព្វផ្សាយរបាយការណ៍ជាតិឆ្នាំ២០២៣ និងលើកទិសដៅ ការងារឆ្នាំ ២០២៤ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស គ.ជ.ប.ជ ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការ ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ មានវត្តមាន អញ្ជើញចូលរួមក្នុងអង្គពិធីមាន ថ្នាក់ដឹកនាំក្រសួង-ស្ថាប័នជាប្រធាននិង អនុប្រធាន សមាជិក នៃក្រុមការងារអន្តរក្រសួងទាំង៦ នៃគ.ជ.ប.ជ ឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិការ នៃគ.ជ.ប.ជ និងរាជរដ្ឋាភិបាល ថ្នាក់ដឹកនាំរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ លោកជំទាវ អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធានលេខាធិការដ្ឋាន ប្រធាននៃក្រុមជំនួយកិច្ចការទាំង៦ មន្ត្រីបច្ចេកទេស មន្ត្រីរបាយការណ៍ មន្ត្រីក្រោម ឱវាទ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ឯកឧត្តម លោកជំទាវ អភិបាល អភិបាលរងជាប្រធាន គ.ខ.ប.ជ និងប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ នៃគណៈអភិបាលរាជធានី-ខេត្តទាំង ២៥ លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត កុងស៊ុល និងតំណាងបេសកកម្មនៃបណ្តាប្រទេសជាមិត្តប្រចាំនៅ កម្ពុជា ជាប្រធាន ឬតំណាងអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការសង្គមស៊ីវិល ដែលកំពុងធ្វើសកម្មភាពនៅ ក្នុងព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធជាច្រើនរូប ។

តំណាងអង្គការ CWCC បានចូលរួមយុទ្ធនាការ ១៦ថ្ងៃប្រឆាំងអំពើហិង្សាលើស្ត្រី ដែលរៀបចំដោយក្រសួងកិច្ចការនារីថ្នាក់ជាតិ និងមន្ទីរកិច្ចការនារីខេត្តកំពង់ស្ពឺ និងសៀមរាបថ្នាក់ខេត្ត។ យុទ្ធនាការនេះមានគោលបំណងលើកកម្ពស់ការយល់ដឹង និងជំរុញការចូលរួមក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើ ហិង្សាលើយេនឌ័រ ដែលផ្តោតលើការផ្សព្វផ្សាយ យុទ្ធនាការ ១៦ថ្ងៃ ដើម្បីបញ្ចប់អំពើហិង្សាលើស្ត្រី និងកុមារី ដោយប្រមូលមតិយោបល់ពីយុវជន អាជ្ញាធរមូលដ្ឋាន អ្នកដឹកនាំសាសនា និងសាធារណជន លើការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការបញ្ចប់អំពើហិង្សាបែបនេះ។

ក្រុមការងារអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ បានចូលរួមក្នុងកិច្ចប្រជុំប្រចាំត្រីមាស ក្រុមការងារឆ្លើយតបអំពើហិង្សាទាក់ទងយេនឌ័រនៅថ្នាក់ខេត្តគោលដៅរួមមានខេត្តកំពង់ស្ពឺ និងសៀមរាប ដើម្បីធ្វើបច្ចុប្បន្នភាពវឌ្ឍនភាព ពង្រឹងសមត្ថភាពក្រុមការងារឆ្លើយតបអំពើហិង្សាទាក់ទងយេនឌ័រនៅថ្នាក់ស្រុក និង

ក្រុមគាំទ្រស្ត្រី និងពិភាក្សាអំពីអន្តរាគមន៍ករណី ដោយផ្តោតលើការធានាគុណភាពនៃការគ្រប់គ្រងករណី និងការផ្តល់សេវា។ លើសពីនេះទៀត ការពិភាក្សា លើសូចនាករ PE11 និង PE13 បានធ្វើអោយប្រសើរឡើងនូវការតាមដានវឌ្ឍនភាព ខណៈពេលដែលការស្ទង់ មតិការពេញចិត្តរបស់អតិថិជនបានផ្តល់មតិកែលម្អដ៏មានតម្លៃសម្រាប់ការបង្កើនគុណភាពសេវាកម្ម។ ការចូល រួមនេះបានរួមចំណែកដល់ការបង្កើតផែនការសកម្មភាពរួមសម្រាប់ត្រីមាសបន្ទាប់ ដោយធានាបាននូវអន្តរាគមន៍ករណីអំពើហិង្សាទាក់ទងយេនឌ័រប្រកបដោយប្រសិទ្ធភាព និងឆ្លើយតបកាន់តែច្រើន និងការគាំទ្រសេវាកម្មសំខាន់ៗដែលមានគុណភាពខ្ពស់សម្រាប់ជនរងគ្រោះ។

អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ បានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលខេត្ត (PCC) ទាំងនៅខេត្តកំពង់ស្ពឺ និខេត្តសៀមរាប។ ក្នុងអំឡុងពេលកិច្ចប្រជុំទាំងនេះ ក្រុមការងារបាន ចែករំលែកវឌ្ឍនភាពនៃការអនុវត្តគម្រោង ដោយលើកឡើងពីសមិទ្ធិផលសំខាន់ៗ បញ្ហាប្រឈម និងហានិភ័យ ដែលបានជួបប្រទះក្នុងការដោះស្រាយអំពើហិង្សាទាក់ទងយេនឌ័រ។ ការពិភាក្សាបានផ្តល់នូវវេទិកាមួយដើម្បី ដោះស្រាយបញ្ហាទាំងនេះ និងធានាឱ្យស្របទៅនឹងផែនការ ACCESS 2 សម្រាប់ឆ្នាំ ២០២៥។ មតិកែលម្អ និងអនុសាសន៍ពីសមាជិក PCC គឺជាធាតុចូលដ៏មានតម្លៃសម្រាប់ការកែសម្រួលផែនការសកម្មភាព ជាពិសេស ក្នុងការធានាគុណភាពនៃសេវាកម្មដែលផ្តល់ដល់អ្នកនៅរស់ បង្កើនការរួមបញ្ចូលពិការភាព និងការកែលម្អ គំនិតផ្តួចផ្តើមស្តារនីតិសម្បទា។ កិច្ចសហការនេះបានពង្រឹងការសម្របសម្រួល និងធានាថាគម្រោងនៅតែបន្ត បំពេញតាមគោលបំណងរបស់ខ្លួន និងសូចនាករដែលបានបង្កើតឡើង។

បុគ្គលិកគម្រោងអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ បានចូលរួមសិក្ខាសាលាការប្រមូលផ្តុំអ្នកពាក់ព័ន្ធក្នុងតំបន់ស្តីពី "ការស៊ើបអង្កេតដែល ផ្តោតលើជនរងគ្រោះនៃករណី SEAH" ដែលរៀបចំឡើងដោយអង្គការសម្ព័ន្ធ CHS Alliance ។ ការចូលរួមរបស់បុគ្គលិក គម្រោងក្នុងវគ្គនេះ បានបង្កើនការយល់ដឹងអំពីការស៊ើបអង្កេត SEAH នៅក្នុងក្របខ័ណ្ឌដែលផ្តោតលើ ជនរងគ្រោះ។ តាមរយៈការផ្តល់ជាធាតុចូលសម្រាប់ការអនុវត្ត និងយុទ្ធសាស្ត្រជាក់ស្តែង ក្នុងការអនុវត្តការ ស៊ើបអង្កេត SEAH ប្រកបដោយប្រសិទ្ធភាព។ ធាតុចូលនេះជាផែនទីបង្ហាញផ្លូវ រួមទាំងពេលវេលា ប្រភពមូលនិធិ និងយុទ្ធសាស្ត្រនិរន្តរភាព។ ធាតុចូលនេះនឹងធ្វើអោយប្រសើរឡើងនូវគុណភាពនៃ ការស៊ើបអង្កេតដែលផ្តោតលើជនរងគ្រោះនៅក្នុងអង្គការបង្កើនផលជះលើការដោះស្រាយការកេងប្រវ័ញ្ច ផ្លូវភេទ និងការរំលោភបំពាន។

បុគ្គលិកគម្រោងបានចូលរួមកិច្ចប្រជុំបច្ចេកទេស ស្តីពីការពិនិត្យរបាយការណ៍ប្រយុទ្ធប្រឆាំងការជួញដូរមនុស្សដែលដឹកនាំដោយ ដែលរៀបចំឡើងដោយ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ។ ក្នុងកិច្ចពិភាក្សាបុគ្គលិកគម្រោងបានផ្តល់ធាតុចូល ដល់ការពិនិត្យឡើងវិញ និងអនុម័តរបាយការណ៍ វឌ្ឍនភាពឆ្នាំ ២០២៤ ស្តីពីកិច្ចខិតខំប្រឹងប្រែងប្រឆាំងការជួញដូរមនុស្ស។ ធាតុចូលនេះជាផ្នែកមួយក្នុងការលើកផែនការការងារឆ្នាំ ២០២៥ ដោយធានាបាននូវវិធីសាស្ត្រដ៏ប្រសើរក្នុង ការដោះស្រាយបញ្ហាទាក់ទងនឹងអំពើជួញដូរមនុស្ស ជាមួយភាគីពាក់ព័ន្ធទាំងអស់។

បុគ្គលិកគម្រោងបានចូលរួមសិក្ខាសាលាពហុភាគីពាក់ព័ន្ធជាតិស្តីពី សិទ្ធិពលករចំណាកស្រុកសម្រាប់ប្រទេសជប៉ុន ដែលដឹកនាំដោយអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី ។

បុគ្គលិកគម្រោងបានរួមចំណែកយ៉ាងសកម្មក្នុងការកំណត់តម្រូវការព័ត៌មានសំខាន់ៗសម្រាប់ ពលករចំណាកស្រុកទៅកាន់ប្រទេសជប៉ុន។ ធាតុចូលនេះមានសារៈសំខាន់ក្នុងការអភិវឌ្ឍកញ្ចប់ ព័ត៌មានបណ្តោះអាសន្ន ដែលនឹងបម្រើជាធនធានដ៏សំខាន់សម្រាប់ពលករចំណាកស្រុក។ សិក្ខាកាមបានដើរ តួនាទីសំខាន់ក្នុងការកំណត់យុទ្ធសាស្ត្រផ្សព្វផ្សាយសម្រាប់ដំណាក់កាលចំណាកស្រុកផ្សេងៗគ្នា ដោយធានា ថាព័ត៌មានទៅដល់ជនចំណាកស្រុកនូវចំណុច ដែលពាក់ព័ន្ធបំផុតនៃការធ្វើដំណើររបស់ពួកគេ ចាប់ពីការសម្រេចចិត្ត រហូតទៅដល់ប្រទេសជប៉ុន។

បុគ្គលិកគម្រោងបានចូលរួម ការចាប់ផ្តើមគម្រោងលើការថែទាំបន្តសម្រាប់ជនរងគ្រោះពីការជួញដូរ មនុស្សឆ្លងដែន ដែលដឹកនាំដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ បុគ្គលិកគម្រោងបានចែករំលែកបទពិសោធន៍ និងការអនុវត្តល្អ ក្នុងការបង្កើនការថែទាំ ជនរងគ្រោះពីការជួញដូរមនុស្ស ដែលបានរួមចំណែកការយល់ដឹង ក្នុងការសិក្សាដែលកំពុងបន្តនៃការអនុវត្ត ការថែទាំបន្ត។ ។ ធាតុចូលនេះបានជួយកំណត់មេរៀនសំខាន់ៗសម្រាប់ការពង្រឹងការថែទាំជនរងគ្រោះ ដោយធានាថា គម្រោងនេះនៅតែផ្តោតលើការផ្តល់សេវាកម្មដ៏មានគុណភាព និងប្រសិទ្ធភាពដល់ជនរងគ្រោះ ចាប់ពីការជួយសង្គ្រោះតាមរយៈការបញ្ជូនត្រឡប់មកវិញ និងការធ្វើសមាហរណកម្មឡើងវិញ។ ធាតុចូលនេះមានសារៈសំខាន់ក្នុងការបង្កើនផលជះរបស់គម្រោងលើជនរងគ្រោះនៃការជួញដូរមនុស្សឆ្លងដែន។

អ្នកសម្របសម្រួលគម្រោងនៃ CWCC បានចូលរួមសិក្ខាសាលាស្តីពីការបង្កើតផែនការសកម្មភាពសម្រាប់ការអនុវត្តគោលនយោបាយការពារកុមារនៅក្នុងសាលារៀន ២០២៤-២០២៨ សិក្ខាសាលានេះធ្វើឡើងនៅមហាវិទ្យាល័យបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាបដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡា។ គោលបំណង គឺពិនិត្យមើលវឌ្ឍនភាព និងវាយតម្លៃ ការអនុវត្តផែនការសកម្មភាពសម្រាប់គោល នយោបាយការពារកុមារនៅក្នុងសាលារៀនឆ្នាំ២០១៩-២០២៣ ក៏ដូចជាកំណត់គោលដៅសម្រាប់ឆ្នាំ ២០២៤-២០២៨។ សិក្ខាសាលានេះមានគោលបំណង រៀបចំសេចក្តី ព្រាងផែនការសកម្មភាពសម្រាប់ ការអនុវត្តគោលនយោបាយគាំពារកុមារនៅតាមសាលារៀនឆ្នាំ២០២៤-២០២៨។

អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ បានគាំទ្រក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (CNCC) ក្នុងការប្រារព្ធសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់តំបន់ ស្តីពីផែនការសកម្មភាពជាតិសម្រាប់ការបង្ការ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារឆ្នាំ ២០២៤-២០២៨ នៅថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០២៤ នៅខេត្តព្រះសីហនុ និងថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០២៤ នៅខេត្តបាត់ដំបង។ គោលបំណងនៃសិក្ខាសាលាគឺ (១) ពិនិត្យ និងផ្តល់ធាតុ ចូលលើសេចក្តីព្រាងផែនការជាតិ និង (២) ចែករំលែកបទពិសោធន៍ និងការអនុវត្តល្អៗ ពីក្រសួង ស្ថាប័នពាក់ព័ន្ធពាក់ព័ន្ធនឹងយន្តការទប់ស្កាត់ និងឆ្លើយតបនឹងអំពើហិង្សាលើកុមារ។ សិក្ខាសាលានេះបានសម្របសម្រួលកិច្ចពិភាក្សា និងកិច្ចសហប្រតិបត្តិការក្នុងន័យស្ថាបនាក្នុងចំណោម តំណាងចំនួន ១៤៥ នាក់ (អ្នកចូលរួម ៦០នាក់នៅក្នុងសិក្ខាសាលាខេត្តព្រះសីហនុ និង៨៥នាក់នៅខេត្តបាត់ដំបង) មកពីក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានា។

អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ បានសម្របសម្រួលការចូលរួមរបស់តំណាងកុមារ និងយុវជនចំនួនប្រាំមួយនាក់មកពីខេត្តកំពង់ធំ (CWCC) ពោធិ៍សាត់ (COCD) និងកំពង់ឆ្នាំង (VCAO) ក្នុងសិក្ខាសាលា ពិគ្រោះយោបល់រយៈពេលពីរថ្ងៃស្តីពី "ការការពារ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ

២០២៤-២០២៨" នៅខេត្តសៀមរាប។ សិក្ខាសាលានេះមានគោលបំណងចូលរួមចំណែកក្នុងផែនការសកម្មភាពជាតិសម្រាប់ ការបង្ការ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារឆ្នាំ ២០២៤-២០២៨ ដោយសង្កត់ធ្ងន់លើសារៈសំខាន់ របស់កុមារ និងយុវជនក្នុងការតស៊ូមតិដើម្បីសិទ្ធិរបស់ពួកគេ។ អ្នកចូលរួមប្រមាណ ១២០ នាក់ រួមទាំង តំណាងក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ បានចូលរួមក្នុងព្រឹត្តិការណ៍នេះ។ តាមរយៈការពិភាក្សាជាក្រុម តំណាងកុមារបានសម្តែងការព្រួយបារម្ភទាក់ទងនឹងការការពារកុមារ វិន័យជាវិជ្ជមាននៅក្នុងសាលារៀន និងការទទួលបានការអប់រំ ICT ដោយធានាថាសំឡេងរបស់ពួកគេត្រូវបានដាក់បញ្ចូលទៅក្នុងផែនការ សកម្មភាពជាតិ។ កុមារពីរនាក់មកពីគម្រោង EVAC កំពង់ធំ (CWCC) ត្រូវបានជ្រើសរើសឱ្យចូលរួមក្នុង កិច្ចប្រជុំពិគ្រោះយោបល់នៅរាជធានីភ្នំពេញនៅថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០២៤។ លើសពីនេះ សមាជិកនៃ ក្លឹបកុមារ E-VAC បានអានសេចក្តីថ្លែងការណ៍រួមមួយទៅកាន់អ្នកបង្កើតគោលនយោបាយ និងអ្នក ពាក់ព័ន្ធ។

តំណាងអង្គការ CWCC បានចូលរួមក្នុងកិច្ចប្រជុំអន្តរក្រសួងស្តីពីផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារឆ្នាំ ២០២៤-២០២៨ ដែលរៀបចំដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (CNCC) នៅថ្ងៃទី ១៦-១៧ ខែតុលា ឆ្នាំ ២០២៤ នៅខេត្តកំពត។ កិច្ចប្រជុំនេះមានអ្នកចូលរួមចំនួន ៤៥នាក់ រួមទាំងតំណាងមកពីអង្គការក្រៅរដ្ឋាភិបាល និងមន្ត្រីរដ្ឋាភិបាលផងដែរ។ ការចូលរួមនេះបាន រួមចំណែកដល់ការអភិវឌ្ឍន៍ជាបន្តបន្ទាប់នៃផែនការសកម្មភាពជាតិ ដោយធានាថាទស្សនវិស័យ និង អាទិភាពរបស់អ្នកពាក់ព័ន្ធសំខាន់ៗត្រូវបានដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រដោះស្រាយ និងទប់ស្កាត់អំពើ ហិង្សាលើកុមារ។

អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC) បានចូលរួមចំណែកគាំទ្រក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (CNCC) ក្នុងការរៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពការងារប្រចាំឆ្នាំរបស់ VAC និងក្រុមការងារ បច្ចេកទេស កសាងសមត្ថភាព នៅថ្ងៃទី ១៩-២០ ខែធ្នូ ឆ្នាំ ២០២៩ នៅខេត្តព្រះសីហនុ។ សិក្ខាសាលានេះមានគោល បំណងលើកកម្ពស់ការយល់ដឹងអំពីការការពារកុមារតាមអ៊ីនធឺណិត និងក្រៅបណ្តាញស្របតាម VAC និងបរិបទបច្ចេកវិជ្ជាសកល និងជំរុញការចូលរួមពីក្រុមហ៊ុនបច្ចេកវិទ្យាក្នុងវិស័យការពារកុមារ ជាពិសេស ក្នុងការឆ្លើយតបទៅនឹង SDG ២០៣០ និងការជូនដំណឹងអំពីវឌ្ឍនភាពការងារសមិទ្ធិផលការងារទាក់ទង នឹង VAC និងទិសដៅការងារឆ្នាំ ២០២៥ នៃវិស័យការងារអន្តរក្រសួង និងដៃគូ NGO ។ អ្នកចូលរួម សរុបចំនួន ៥២ នាក់ (ស្រី ១៤ នាក់) ដែលរួមមានមន្ត្រីរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធសំខាន់ៗ បានចូលរួម ក្នុងសិក្ខាសាលានេះ និងបានចូលរួមចំណែកក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រ។ ជាមួយគ្នានេះ កម្ពុជាកំពុងរៀបចំសេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពីការបញ្ចប់អំពើហិង្សាលើកុមារ ឆ្នាំ២០២៤-២០៣០ និងសេចក្តីព្រាងច្បាប់ស្តីពីការការពារកុមារ។ ក្នុងសិក្ខា សាលានេះ តំណាង CWCC បានចែក រំលែកការយល់ដឹងអំពីគម្រោង EVAC និងបានលើកឡើងពីសេវាកម្មដ៏ទូលំទូលាយរបស់ CWCC ដែលជួយដល់ស្ត្រី និងកុមារីដែលរួចរស់ជីវិតពីអំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពាន និងការជួញដូរ។ អ្នកចូលរួម រួមទាំងតំណាងមកពីក្រសួងកិច្ចការនារី បានសម្តែងការទទួលស្គាល់ និងវាយតម្លៃខ្ពស់ ចំពោះគម្រោង EVAC ដោយកត់សម្គាល់ការតម្រឹមរបស់វាជាមួយនឹងក្របខ័ណ្ឌជាតិសំខាន់ៗដូចជា NAPVAC NAPVAW IV និង Neary Ratanak 6។

ការទទួលស្គាល់នេះបានគូសបញ្ជាក់ពីភាពពាក់ព័ន្ធ របស់គម្រោង និងការរួមចំណែកក្នុងការការពារកុមារ និងបន្ត។

អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC) COCD VCAO និងតំណាងកុមារបានចូលរួមក្នុងការប្រារព្ធខួបលើកទី 75 នៃទិវាកុមារអន្តរជាតិ និងកុមារកម្ពុជាឆ្នាំ 2024 ក្រោមប្រធានបទ "ការវិនិយោគលើកុមារថ្ងៃនេះមានគោលបំណងបង្កើនធនធានមនុស្សក្នុងបដិវត្តន៍ឌីជីថល"។ ជាមួយគ្នានេះដែរ កុមារក៏បានចូលរួមប្រារព្ធខួបលើកទី 23 នៃទិវាពិភពលោកប្រឆាំងពលកម្មកុមារក្រោមប្រធានបទ "រួមគ្នាអនុវត្តការប្តេជ្ញាចិត្តដើម្បីបញ្ចប់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ" ដែលបានទាក់ទាញអ្នកចូលរួមប្រមាណ 3,000 ។

អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC) បានសម្របសម្រួលកុមារចំនួន ០៦នាក់ មកពីអង្គការ CWCC ខេត្តកំពង់ធំ, COCD ខេត្តពោធិ៍សាត់, និង VCAO ខេត្តកំពង់ឆ្នាំង ចូលរួមក្នុងវេទិកាកុមារ និងអ្នកធ្វើគោលនយោបាយក្រោមប្រធានបទ "វិនិយោគលើកុមារថ្ងៃនេះ សំដៅបង្កើនមូលធនមនុស្សក្នុងយុគសម័យបរិវត្តកម្មឌីជីថល" ដែលវេទិកានេះផ្តោតលើការវិនិយោគលើកុមារថ្ងៃនេះសំដៅបង្កើនមូលធនមនុស្សក្នុងយុគសមបរិវត្តកម្មឌីជីថល នាទីស្តីការក្រសួងសង្គមកិច្ចអតីតយុវជន និងយុវនីតិសម្បទាន ដោយមានកិច្ចសហការពីក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ, អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា និងសមាគមន៍ចលនា និងយុវជនដើម្បីសិទ្ធកុមារ រួមទាំងស្ថាប័ន អង្គការ ពាក់ព័ន្ធជាច្រើនទៀតចូលរួមផងដែរ ដែលមានអ្នកចូលរួមចំនួនប្រមាណ១៥៦នាក់។ ក្នុងវេទិកាពិភាក្សា តំណាងកុមារទាំង៦នាក់ បានមានឱកាសលើកឡើងនូវសំណួរដែលផ្សារភ្ជាប់បញ្ហានិងកង្វល់របស់កុមារទៅដល់អ្នកធ្វើគោលនយោបាយ ដើម្បីជាការឆ្លើយតបទៅនឹងតម្រូវការ និងដោះស្រាយបញ្ហារបស់កុមារនៅតាមសហគមគោលដៅ។

បុគ្គលិកគម្រោងបានចូលរួមសិក្ខាសាលាថ្នាក់ជាតិស្តីពីវិធីសាស្ត្រដែលផ្តោតលើយេនឌ័រ និងជនរងគ្រោះ ដើម្បីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា ដែលរៀបចំដោយក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា គាំទ្រដោយ Australian Aid ។ សិក្ខាសាលាបានផ្តោតលើការលើកកម្ពស់ និងការធ្វើសមាហរណកម្មសង្គម គោលការណ៍ណែនាំរបស់អាស៊ាន ដោយសង្កត់ធ្ងន់លើសារៈសំខាន់នៃការធ្វើសមាហរណកម្ម វិធីសាស្ត្រដែលផ្តោតលើយេនឌ័រ និងជនរងគ្រោះនៅក្នុងកិច្ចខិតខំប្រឹងប្រែងប្រឆាំងការជួញដូរ។ អ្នកចូលរួម មានតំណាងមកពីទីភ្នាក់ងាររដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ និងមេដឹកនាំសហគមន៍ ដែលបានពិភាក្សាអំពីការអនុវត្តល្អៗ ចែករំលែកបទពិសោធន៍ និងបង្កើតយុទ្ធសាស្ត្រដើម្បីបង្កើនប្រសិទ្ធភាព នៃគំនិតផ្តួចផ្តើមប្រឆាំងការជួញដូរនៅកម្ពុជា។

នាយកប្រតិបត្តិនៃ CWCC បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី NAPVAW IV 2024-2030 ដែលដឹកនាំដោយ TWGG-GBV។ សិក្ខាសាលានេះមានគោលបំណងពិនិត្យ និងបញ្ចប់ NAPVAW IV ដោយធានានូវការចូលរួម និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធសំខាន់ៗក្នុងការឆ្លើយតប និងការត្រួតពិនិត្យ។ សិក្ខាសាលាពិគ្រោះយោបល់ក៏បានស្វែងរកការប្រមូលធាតុចូលពីអ្នកចូលរួមទាក់ទងនឹងការអភិវឌ្ឍន៍សូចនាករ និងក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃ។ ក្នុងសិក្ខាសាលា នាយកប្រតិបត្តិនៃ CWCC បានសម្របសម្រួលការពិភាក្សាជាក្រុមលើផ្នែកអនុយុទ្ធសាស្ត្រនៃការសម្របសម្រួលពហុវិស័យ និងគុណភាពនៃសេវាសំខាន់ៗ។

### ៣.២ ការងារជាបណ្តាញ

អង្គការ CWCC បានចូលរួមក្នុងកិច្ចប្រជុំ GBV ដឹកនាំដោយ UNFPA នៅថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ ២០២៤។ ការធ្វើបច្ចុប្បន្នភាព និងសកម្មភាពសំខាន់ៗត្រូវបានពិភាក្សាទាក់ទងនឹងកិច្ចខិតខំប្រឹងប្រែងស្តីពីអំពើហិង្សាទាក់ទងយេនឌ័រនៅក្នុងប្រទេសកម្ពុជា។ ធនាគារពិភពលោកបានបង្ហាញគម្រោងផែនទីសេវាកម្ម GBV រយៈពេលពីរឆ្នាំរបស់ពួកគេ ដែលកំណត់គោលដៅ ២៥ ខេត្តដើម្បីកំណត់គម្លាតនៃសេវាកម្ម និងវាយតម្លៃ លទ្ធភាពប្រើប្រាស់។ UN Women បានធ្វើបច្ចុប្បន្នភាពលើការអភិវឌ្ឍន៍ NAP-VAW លើកទី ៤ ហើយបានប្រកាសសិក្ខាសាលាពិគ្រោះយោបល់ដែលគ្រោងធ្វើនៅខែតុលា។ CARE បានពិភាក្សាអំពីផលប៉ះពាល់សេដ្ឋកិច្ចរបស់ GBV នៅក្នុងវិស័យកាត់ដេរ និងបានតស៊ូមតិសម្រាប់ការអនុវត្តច្បាប់ GBVH កាន់តែប្រសើរ។ អង្គការយូនីសេហ្វបានចែករំលែក SOP ការការពារកុមាររបស់ពួកគេ ដោយផ្តោតលើការកសាងសមត្ថភាព និងស្តង់ដារនៃប្រព័ន្ធការពារកុមារ។ ADB បានគូសបញ្ជាក់ពីគម្រោងផ្តល់ជំនួយចំនួន ១០ លានដុល្លារ ក្នុងគោលបំណងពង្រឹងប្រព័ន្ធឆ្លើយតប GBV នៅកម្ពុជា។ កិច្ចប្រជុំបានបញ្ចប់ជា មួយនឹងផែនការសម្រាប់ការពិគ្រោះយោបល់ និងសកម្មភាពនាពេលអនាគត រួមទាំងការធ្វើបច្ចុប្បន្នភាពលើការគ្រប់គ្រងករណី GBV និងការអនុវត្តល្អ។

បុគ្គលិកវាយតម្លៃគម្រោង (M&E) បានចូលរួមក្នុងសិក្ខាសាលាដើម្បីពិនិត្យនិងចុងក្រោយសេចក្តីព្រាងផែនការយុទ្ធសាស្រ្តជាតិ ៥ ឆ្នាំ (២០២៤-២០២៨) ស្តីពីការប្រយុទ្ធនឹងការជួញដូរមនុស្ស។ សិក្ខាសាលានេះបាន ប្រារព្ធឡើងនៅក្រសួងមហាផ្ទៃ និងដឹកនាំដោយលោកជំទាវ ជូ ប៊ុន អេង រដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ និងអនុប្រធានអចិន្ត្រៃយ៍ តំណាងអង្គការ CWCC ។

បុគ្គលិកគម្រោងបានចូលរួមក្នុងការបណ្តុះបណ្តាលអ្នកបណ្តុះបណ្តាល (TOT) ស្តីពីការរួមបញ្ចូល និងការតាមដានជនរងគ្រោះនៃការជួញដូរមនុស្ស និងការរំលោភផ្លូវភេទនៅក្នុងមណ្ឌលរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ ដែលមានឥទ្ធិពលសំខាន់លើគម្រោង ដែលរៀបចំឡើងដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ មន្ត្រីផ្នែកការរួមបញ្ចូលបានទទួលជំនាញ និងចំណេះដឹងសំខាន់ដើម្បីគាំទ្រ និងរួមបញ្ចូលជនរងគ្រោះបានល្អប្រសើរជាងមុន។ ការបណ្តុះបណ្តាលនេះ បានពង្រឹងការសហការរវាងភាគីពាក់ព័ន្ធផ្សេងៗដោយនាំទៅរកប្រព័ន្ធតាមដាន និងគាំទ្រដែលមានប្រសិទ្ធភាព ជាងមុន។

បុគ្គលិកគម្រោងបានចូលរួមកម្មវិធីពិភាក្សាពិគ្រោះយោបល់ និងកិច្ចប្រជុំ ថ្នាក់តំបន់តាមរយៈ Zoom សម្រាប់គម្រោង "ការធានានូវការងារសមរម្យ និងកាត់បន្ថយភាពងាយរងគ្រោះសម្រាប់ស្ត្រី និងកុមារក្នុងបរិបទនៃការធ្វើចំណាកស្រុកការងារនៅអាស៊ីអាគ្នេយ៍" (PROTECT) មានគោលបំណងដោះស្រាយបញ្ហាប្រឈមរបស់ស្ត្រីនិងកុមារនៅក្នុងតំបន់ ដោយផ្តោតលើការលើកកម្ពស់ការអនុវត្តការងារប្រកបដោយសុវត្ថិភាព និងយុត្តិធម៌ កាត់បន្ថយភាពងាយរងគ្រោះ និងការលើកកម្ពស់ប្រព័ន្ធគាំទ្រសម្រាប់គ្រួសារចំណាកស្រុក។ កិច្ចសន្ទនាបានប្រមូលផ្តុំភាគីពាក់ព័ន្ធសំខាន់ៗ រួមទាំងអ្នកបង្កើតគោលនយោបាយ អង្គការក្រៅរដ្ឋាភិបាល និងអ្នកដឹកនាំសហគមន៍ ដើម្បីពិភាក្សាអំពីយុទ្ធសាស្រ្ត និងកិច្ចខិតខំប្រឹងប្រែងរួមគ្នាសម្រាប់ការអនុវត្តគោលដៅរបស់គម្រោងប្រកបដោយប្រសិទ្ធភាព។

### ៣.៣ យុទ្ធនាការស្វែងរកមតិគាំទ្រ

អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ បានសហការជាមួយអាជ្ញាធរនិងអ្នកពាក់ព័ន្ធក្នុងការរៀបចំយុទ្ធនាការ ១៦ថ្ងៃ ប្រឆាំងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្រោមប្រធានបទ "រួមគ្នាវិនិយោគលើការទប់ស្កាត់អំពើហិង្សា

លើស្ត្រីនិងក្មេងស្រី" ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងបញ្ហាប្រឈមទាក់ទងនឹងឥរិយាបទរើសអើងលើស្ត្រីនិងក្មេងស្រីនិងលើកទឹកចិត្តឱ្យចូលរួមបញ្ឈប់អំពើហិង្សាទាក់ទងនឹងយេនឌ័រ ព្រមទាំងអំពាវនាវឱ្យមានការធ្វើឱ្យប្រសើរឡើងនូវការទទួលបានសេវានានារួមទាំង សេវាផ្លូវច្បាប់ ។ យុទ្ធនាការនេះបានប្រារព្ធឡើងនៅៈ

ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៤ អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ បានសហការជាមួយ មន្ទីរកិច្ចការនារីខេត្ត និង រដ្ឋបាលស្រុកសាមគ្គីមុនីជ័យ ខេត្តកំពង់ស្ពឺបានរៀបចំយុទ្ធនាការ ១៦ថ្ងៃបញ្ឈប់អំពើហិង្សាលើស្ត្រីនិងក្មេងស្រីឆ្នាំ២០២៤ ក្រោមប្រធានបទរួមគ្នា បញ្ឈប់អំពើហិង្សាលើស្ត្រីដើម្បីវឌ្ឍនភាពសង្គម និងពិភពលោក នៅស្រុកសាមគ្គីមុនីជ័យ រៀបចំដោយអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ គាំទ្រពីកម្មវិធី ACCESS2 មានការ ចូលរួមពីអាជ្ញាធរភូមិ ឃុំ ស្រុក លោកគ្រូ អ្នកគ្រូសិស្សានុសិស្ស ប្រជាពលរដ្ឋ ចំនួន២៥៩នាក់ ។

ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២៤ អង្គកម្ពុជាដើម្បីជួយស្ត្រីមានវបត្តិ ប្រចាំខេត្តកំពង់ធំ បានសហការជាមួយ អជ្ញាធរស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ បានរៀបចំកម្មវិធីយុទ្ធនាការ១៦ថ្ងៃ ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រីនិងក្មេងស្រី ក្រោមប្រធានបទ "រួមគ្នាបញ្ឈប់អំពើហឹង្សាលើស្ត្រី ដើម្បីវឌ្ឍនភាពសង្គមនិងពិភព លោក" កម្មវិធីនេះប្រារព្ធឡើងនៅបរិវេណ វត្តក្រយា ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ដែលមានអ្នកចូលរួមសរុបចំនួន ៣១៩ នាក់ (ស្រី១៨១នាក់)។

ថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ ២០២៤ អង្គកម្ពុជាដើម្បីជួយស្ត្រីមានវបត្តិ ប្រចាំខេត្តកំពង់ធំ បានសហការជាមួយ អជ្ញាធរស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ បានរៀបចំកម្មវិធីទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ ខួបលើកទី១៨ក្រោមប្រធានបទ "កម្ពុជាប្រឆាំងដាច់ខាតអំពើជួញដូរមនុស្សគ្រប់ទម្រង់និងគ្រប់មធ្យោបាយក្នុងយុគសម័យឌីជីថល២០២៤" គោលបំណងនៃការប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ១២ធ្នូនេះគឺដើម្បីបង្កើនការយល់ដឹងដល់សាធារណៈជនពីអំពើជួញដូរមនុស្ស និងកេងប្រវ័ញ្ចគ្រប់រូបភាពជាពិសេសកុមារ និងផលវិបាកនៃការធ្វើចំណាកស្រុកដោយប្រថុយប្រថាន។ កម្មវីធីនេះប្រារព្ធឡើងនៅបរិវេណសាលាឃុំត្រពាំងឫស្សី ក្រោមអធិបតីភាព លោកជំទាវ លំ គន្ធារី អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តកំពង់ធំ និង លោក លោកស្រីប្រធានមន្ទីរពាក់ព័ន្ធ លោកស្រី អភិបាលរងស្រុក លោកមេឃុំនិងសហការី នាយប៉ុស្តិ៍ អង្គការដៃគូ លោកគ្រូ អ្នកគ្រូសិក្សានុសិស្ស និង ប្រជាពលរដ្ឋ សរុបចំនួន ៣០៣នាក់ ស្រី ១៨២នាក់។

## ៤. កម្មវិធីអភិវឌ្ឍន៍អង្គការ

### ៤.១ នាយកក្រុមប្រឹក្សាភិបាល

នាយកក្រុមប្រឹក្សាភិបាលនៃអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ មានប្រាំរូបដែលជាអ្នកដឹកនាំក្រុមអង្គការសិទ្ធិមនុស្សដ៏លេចធ្លោនៅកម្ពុជាៈ (១) ប្រធានក្រុមប្រឹក្សាភិបាល លោកមេធាវី សុក សំអឿន ជានាយកប្រតិបត្តិនៃក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ដែលជាអង្គការជំនួយផ្នែក ច្បាប់ដ៏លេចធ្លោនៅក្នុងប្រទេសកម្ពុជា (២) លោកស្រី លឹម ស៊ាវហុង ជាទីប្រឹក្សានៃអង្គការ Give2Asia ប្រចាំប្រទេសកម្ពុជា (៣) លោក ជា ពីដែន គឺជានាយកប្រតិបត្តិអង្គការគាំពារ កុមារងាយទទួលរងគ្រោះ (VCAO) ដែលធ្វើការការពារសិទ្ធិកុមារ និងលើកកម្ពស់ការចូលរួមរបស់កុមារ (៤) លោកស្រី ប៉ែន មនោរម្យ ដែលបច្ចុប្បន្នជា

នាយិការរងអង្គការ PSI និង (៥) លោកស្រី កុយ ផល្លានី ជានាយិកាប្រតិបត្តិនៃអង្គការខេមរា។

**៤.២ បុគ្គលិករបស់អង្គការ**

ក្នុងឆ្នាំ២០២៤ បុគ្គលិកអង្គការ CWCC សរុបមានបុគ្គលិកសរុបចំនួន៤៨នាក់ (ប្រុស១៤នាក់) ក្នុងនោះ មានបុគ្គលិកដែលមានពិការភាពចំនួន៣នាក់ (១នាក់ជាប្រុស)។ បុគ្គលិកនៅការិយាល័យភ្នំពេញ ១៩នាក់ (ស្រី១៤នាក់) ការិយល័យខេត្តសៀមរាបមាន១៣នាក់ (ស្រី៩នាក់) ការិយាល័យខេត្តបន្ទាយមានជ័យមាន ៧នាក់ (ស្រី៤នាក់) ការិយាល័យខេត្តកំពង់ធំមាន៧នាក់ (ស្រី៥នាក់)។

**៤.៣ ការកសាងសមត្ថភាពបុគ្គលិក**

បុគ្គលិកអង្គការ CWCC បានទទួលការបណ្តុះបណ្តាលដើម្បីលើកកម្ពស់សមត្ថភាពការងារ និងអភិវឌ្ឍបុគ្គលិកឆ្នាំ២០២៤ មានដូចជា៖

១. វគ្គបណ្តុះបណ្តាលគ្រូបង្គោលអំពី "ការផ្លាស់ប្តូរឥរិយាបទទំនាក់ទំនងបែបស្រ្តីនិយម" រៀបចំដោយអង្គការ CARE Cambodia ក្រោមគម្រោង Feminist in Action Project (FiA) កាលពីថ្ងៃទី២៣ - ៣០ ខែមករា ឆ្នាំ២០២៤ នៅសណ្ឋាគារ Paulo Wai Hotel & Apartment ភ្នំពេញ។

២. វគ្គបណ្តុះបណ្តាលអំពី "ជំរើសនៃការដោះស្រាយវិវាទ" រៀបចំដោយ Cambodian Centre for Mediation កាលពីថ្ងៃទី២២៤ ខែ មករា ឆ្នាំ២០២៤ នៅហាងកាហ្វេ ធីម។

៣. វេទិកា ការត្រួតពិនិត្យនិងវាយតម្លៃ រៀនសូត្រ លើកទី៣២ ស្តីអំពី "របៀបគ្រប់គ្រងដំណើរការត្រួតពិនិត្យនិងវាយតម្លៃ គម្រោង/កម្មវិធី" រៀបចំដោយអង្គការ Cooperation Committee for Cambodia (CCC) កាលពីថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០២ នៅការិយាល័យអង្គការ Diakonia Center ។

៤. វគ្គបណ្តុះបណ្តាលអំពី "របៀបប្រើប្រាស់ទម្រង់ឧបករណ៍រូបភាពសំរាប់គាំទ្រដល់កុមារមានពិការភាព ឬលំបាកក្នុងការនិយាយ" រៀបចំដោយអង្គការ OIC កាលពីថ្ងៃទី២៦ - ២៨ ខែមីនា ឆ្នាំ២០២៤ នៅសណ្ឋាគារ Sunway ភ្នំពេញ។ វគ្គបណ្តុះបណ្តាលនេះគ្រោងរៀបចំឡើងចំនួន២វគ្គទៀតនៅថ្ងៃទី០៨ - ១០ ខែឧសភា និង នៅថ្ងៃទី០៥ - ០៧ ខែមិថុនា ឆ្នាំ២០២៤។

៥. វគ្គបណ្តុះបណ្តាលអំពី "សមភាពយេនឌ័រ ពិការភាព និងបរិយាប័នសង្គម" រៀបចំដោយអង្គការ ACCESS 2 កាលពីថ្ងៃទី២៧ - ២៨ ខែ ឧសភា ឆ្នាំ២០២៤ នៅសណ្ឋាគារសោម៉ាទេវី ខេត្តសៀមរាប។

៦. វគ្គបណ្តុះបណ្តាលអំពី "សារាចរ លេខ០១១ ស្តីពីការងារសមាហរណកម្ម និងតាមដានជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទ ដែលបានស្នាក់នៅក្នុងមជ្ឈមណ្ឌលរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍" រៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កាលពីថ្ងៃទី១៧-២១ ខែ មិថុនា ឆ្នាំ២០២៤។

៧. វគ្គបណ្តុះបណ្តាលអំពី "វិន័យបែបវិជ្ជមាន និងការគ្រប់គ្រងថ្នាក់រៀន" រៀបចំដោយអង្គការ CWCC កាលពីថ្ងៃទី២៦-៣០ ខែសីហា ឆ្នាំ២០២៤ នៅសណ្ឋាគារភ្នំពេញ។

៨. ចូលរួមសន្និសិទអាស៊ីឆ្នាំ២០២៤ អំពី "ការផ្តល់ជំរកដល់ស្រ្តី -ការដោះស្រាយអំពើហិង្សាលើយេនឌ័រដែលសម្របសម្រួលតាមប្រព័ន្ធអីនធីណេត និងបច្ចេកវិទ្យានៅអាស៊ី" រៀបចំដោយអង្គការ នៅប្រទេសតៃវ៉ាន់ កាលពីថ្ងៃទី០៩-១៣ ខែកញ្ញា ឆ្នាំ ២០២៤។

៩. វគ្គបណ្តុះបណ្តាលអំពី "កិច្ចការពារកុមារ និងឪពុកម្តាយគំរូ" រៀបចំដោយអង្គការ CWCC

កាលពីថ្ងៃទី ០៧-១១ ខែតុលា ឆ្នាំ២០២៤ នៅសណ្ឋាគារភ្នំពេញ។

១០. វគ្គបណ្តុះបណ្តាល៣ថ្ងៃ អំពី "ការថែរទាំអំពីការប៉ះទង្គិចផ្លូវចិត្ត ដល់កុមាររងគ្រោះ និងគ្រួសារដោយការរំលោភបំពាន និងកេងប្រវ័ញ្ចតាមប្រព័ន្ធអនឡាញ" រៀបចំដោយអង្គការ World Hope កាលពីថ្ងៃទី ២៦-២៨ ខែវិច្ឆិកា ឆ្នាំ ២០២៤ នៅសណ្ឋាគារកាំបូឌីយ៉ាណា។

# ៥. របាយការណ៍ហិរញ្ញវត្ថុសង្ខេប

## ៥.១ ថវិកាហិរញ្ញវត្ថុ ២០២៤

| ម្ចាស់មូលនិធិ | ថវិកា | ភាគរយ |
|---|---:|---:|
| Lotus Outreach | 136,489 | 17.19% |
| AOP | 74,294 | 9.36% |
| TDH-BMZ | 115,841 | 14.59% |
| FWC | 7,985 | 1.01% |
| ILO-PROTECT | 6,715 | 0.85% |
| SOLIDAR | 87,614 | 11.03% |
| ACCESS 2 | 124,206 | 15.64% |
| Rotary Club | 31,147 | 3.92% |
| UNTF | 207,274 | 26.10% |
| Others | 2,574 | 0.32% |
| **Grand Total** | **794,139** | **100.00%** |

## ៥.២ ការចំណាយហិរញ្ញវត្ថុ ២០២៤

| កម្មវិធី | ការចំណាយ | ភាគរយ |
|---|---:|---:|
| Protection Program | 271,996 | 36% |
| Prevention Program | 289,085 | 39% |
| Advocacy Program | 123,500 | 17% |
| Organizational Development Program | 62,075 | 8% |
| **Total** | **746,656** | **100%** |

## ៥.៣ ព័ត៌មានអំពីគណនីធនាគារ របស់អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ

បច្ចុប្បន្នអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ មានគណនីចំនួនសរុប ប្រាំមួយ ប្រាំនៅធនាគារ **អេស៊ីលីដា ភីអិលស៊ី** និង មួយទៀតនៅធនាគារ **ពាណិកម្មក្រៅប្រទេសនៃកម្ពុជា** សំរាប់ទទួលជំនួយ និងទូទាត់ចំណាយផ្សេងៗ ក្នុងការប្រតិបត្តិការគម្រោងរបស់អង្គការទាំងមូល។ គណនីទាំងនេះមានឈ្មោះ និង លេខគណនីដូចខាងក្រោម៖

**ធនាគារអេស៊ីលីដា ភីអិលស៊ី ( ACLEDA Plc Bank)**

| | |
|---|---|
| ១- គណនីឈ្មោះ | **CWCC UNTF** |
| លេខគណនី | ៣៦០០-០៤៦៩១១៨៦-១៦ |
| បច្ចុប្បន្នភាព | ១៣ ខែ កុម្ភៈឆ្នាំ ២០២៥ |
| ២- គណនីឈ្មោះ | **CWCC-ACCESS** |
| លេខគណនី | ២៩០០-០៥១៨៥៣៥៨-១៨ |
| បច្ចុប្បន្នភាព | ១៣ ខែ កុម្ភៈឆ្នាំ ២០២៥ |
| ៣- គណនីឈ្មោះ | **CWCC-TDH-BMZ** |
| លេខគណនី | ២៩០០-០៥១៥៦២៤០-១០ |
| បច្ចុប្បន្នភាព | ១៣ ខែ កុម្ភៈឆ្នាំ ២០២៥ |
| ៤- គណនីឈ្មោះ | **CWCC-Re** |
| លេខគណនី | ២៩០០-២០៦៤២៤៧-១៧ |
| បច្ចុប្បន្នភាព | ១៣ ខែ កុម្ភៈឆ្នាំ ២០២៥ |
| ៥- គណនីឈ្មោះ | **CWCC-HO** |
| លេខគណនី | ២៩០០-១០៧៨៧៨៧៥-១៥ |
| បច្ចុប្បន្នភាព | ១៣ ខែ កុម្ភៈឆ្នាំ ២០២៥ |

**ធនាគារ ពាណិកម្មក្រៅប្រទេស នៃកម្ពុជា (FTB Bank)**

| | |
|---|---|
| ១- គណនីឈ្មោះ | **CWCC-LO** |
| លេខគណនី | ៣០០០០៤៦១៥៤៣៧ |
| បច្ចុប្បន្នភាព | ១៣ ខែ កុម្ភៈឆ្នាំ ២០២៥ |

## ទំនាក់ទំនង៖

### ការិយាល័យកណ្តាលនិងរាជធានីភ្នំពេញ

- អាសយដ្ឋាន៖ #៤២F ផ្លូវ៤៨៨ ផ្សារដើមថ្កូវ ចំការមន ភ្នំពេញ កម្ពុជា
- អាសយដ្ឋានប្រៃសណីយ៖ P.O Box ២៤២១ និង CCC box ៣៥៦
- ទូរស័ព្ទ៖ (៨៥៥-២៣) ៩៨៧១៥៨/០១២ ២៤៣ ៩៨៨
- អ៊ីម៉ែល៖ PNPadmin@cwcc.org.kh PNPmanager@cwcc.org.kh

### ការិយាល័យខេត្តបន្ទាយមានជ័យ

- អាសយដ្ឋាន៖ ភូមិសាមគ្គីមានជ័យ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត
- ទូរស័ព្ទ ៖ (៨៥៥-៥៤) ៩៦៧ ១៩៤/០៨៧ ៩០៩០ ២០
- អ៊ីម៉ែល៖ BMCadmin@cwcc.org.kh BMCmanager@cwcc.org.kh

### ការិយាល័យខេត្តសៀមរាប

- អាសយដ្ឋាន៖ ភូមិបឹងដូនប៉ា សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប
- ទូរស័ព្ទ៖ (៨៥៥-៦៣) ៩៦៣២៧៦/០៩២ ៣៥ ២៤ ២៩
- អ៊ីម៉ែល៖ SRPadmin@cwcc.org.kh SRPmanager@cwcc.org.kh

### ការិយាល័យខេត្តកំពង់ធំ

- អាសយដ្ឋាន៖ ផ្លូវលេខ ៨ ភូមិដំរីជាន់ខ្លា សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ
- ទូរស័ព្ទ៖ (៨៥៥-៦២) ២១០៥១៥/០១៧ ៤៧ ០០ ៨៦
- អ៊ីម៉ែល៖ KPTadmin@cwcc.org.kh KPTmanager@cwcc.org.kh

# សូមថ្លែងអំណរគុណចំពោះម្ចាស់ជំនួយដូចខាងក្រោម

LOTUS OUTREACH CAMBODIA Org.

UNITED NATIONS TRUST FUND TO END VIOLENCE AGAINST WOMEN

Rotary Club of Phnom Penh

Australian Aid

ACCESS 2 – Sustainable quality services for all

Action on Poverty

friendship with CAMBODIA

TERRE DES HOMMES – Empowered Children. A Just World.

german cooperation – DEUTSCHE ZUSAMMENARBEIT

lotus outreach australia – education-opportunity-action

SOLIDAR SUISSE – LUTTER POUR UN MONDE ÉQUITABLE

Funded by the European Union

International Labour Organization

PROTECT

Protection of the Rights of Women and Children in Labour Migration Project (PROTECT) is a joint project implemented by ILO, UN Women, UNICEF and UNODC, funded by the EU.